# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ករណី សួស ធី K09089
## សម្ភាសន៍ជាមួយសួស ធី អាយុ៥២ឆ្នាំ ជាម្ចាស់ប្រវត្តិរូប
## មុខងារសម័យខ្មែរក្រហមៈ អ្នកកាន់បញ្ជីនៅស-២១
## ភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល
## សម្ភាសន៍ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៣
## សម្ភាសន៍ដោយៈ ដាន់ សុដា និងសុខឃាង
## សរុបៈ ៣៨ទំព័រ

សុដាៈ ពូឈ្មោះអីដែរ?

ធីៈ ខ្ញុំឈ្មោះសួស ធី ។

សុដាៈ ពូអាយុប៉ុន្មានដែរ?

ធីៈ អាយុ៥២ឆ្នាំហើយ ។

សុដាៈ នៅក្នុងភូមិពូ នៅរាល់ថ្ងៃនេះភូមិអីដែរ?

ធីៈ ភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាងខេត្តកណ្តាល ។

សុដាៈ ចុះពូមានស្រុកកំណើតនៅខាងណាដែរ?

ធីៈ ខ្ញុំស្រុកកំណើតនៅណឹងតែម្តង ។

សុដាៈ កាលណឹងគេមានដូរជាភូមិ ឃុំអីដែរ?

ធីៈ អត់ទេ ។

សុដាៈ ពូមានឈ្មោះហៅក្រៅទេ?

ធីៈ អត់ទេ ។

សុដាៈ ឪពុកពូឈ្មោះអីដែរ?

ធីៈ ឈ្មោះ សួស ធុយ ។

សុជាៈ ហើយគាត់នៅរស់ដែរអត់ទេរាល់ថ្ងៃណឹង?

ធីៈ ស្លាប់ហើយ ។

សុជាៈ ចុះម្តាយ?

ធីៈ ញ៉ឹម វឿន ។

សុជាៈ ស្លាប់ដែរ?

ធីៈ បាទ ។

សុជាៈ ហើយពួកគាត់ស្លាប់ពីពេលណាមកដែរ?

ធីៈ ឪពុកខ្ញុំស្លាប់តាំងពីឆ្នាំ៧០ ។

សុជាៈ ស្លាប់ដោយសារកាលណឹង?

ធីៈ ដោយជំងឺ ។

សុជាៈ ចុះម្តាយ?

ធីៈ ម្តាយខ្ញុំស្លាប់ពីរបីឆ្នាំហើយ ។

សុជាៈ ពូគ្រួសារពូឈ្មោះអីដែរ?

ធីៈ ឈ្មោះសុខ ចាន់ថា ។

សុជាៈ ហើយរាល់ថ្ងៃពូមានកូនចៅប៉ុន្មាននាក់?

ធីៈ បីនាក់ ។

សុជាៈ ចុះបងប្អូនពូប៉ុន្មាននាក់ ទាំងអ្នកបាត់ អ្នកនៅអីណឹង?

ធីៈ បងប្អូនទាំងអស់៨នាក់ ។

សុជាៈ ឥឡូវនៅសល់ប៉ុន្មានដែរ?

ធីៈ បាត់អស់៤នាក់ ។

សុជាៈ បាត់នៅពេលណាដែរ?

ធីៈ បាត់នៅសម័យប៉ុល ពត ។

សុជាៈ ទាំងបួននាក់ណឹង?

ធីៈ បាទ កាលពីមុនគាត់ធ្វើការនៅជំនាន់ លន់ ណល់?

សុជាៈ អ ពួកគាត់ខាងលន់ ណល់?

ធី៖ បាទ ។

សុជា៖ តែគាត់ណឹងដឹងថាបាត់ រឺដឹងស្លាប់តែម្តង?

ធី៖ ស្លាប់ដូចថាកាលបងខ្ញុំពីរនាក់ណឹងគេចាប់ខ្លួននៅកោះគណឹង ។

សុជា៖ ចុះស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ធី៖ បាត់ណឹង?

សុជា៖ បាទ?

ធី៖ ស្រីមួយប្រុសបី ។

សុជា៖ ចុះពូកើតនៅក្នុងឆ្នាំណាដែរ?

ធី៖ ឆ្នាំ១៩៥២ ។

សុជា៖ ហើយកាលមុន៧៥ ពូនៅឯណាដែរ?

ធី៖ មុន៧៥និយាយត្រឹមឆ្នាំ៧០ណឹង ។

សុជា៖ បាទ ពេលមុន៧៥ ពេលមិនទាន់បដិវត្តន៍ មិនទាន់ចូលជួរចូលអី?

ធី៖ ពីមុនខ្ញុំនៅរៀន ។

សុជា៖ រៀននៅឯណា?

ធី៖ រៀននៅភូមិកោះខែលយើងណឹង ។

សុជា៖ រៀនដល់ថ្នាក់ទីប៉ុន្មាន?

ធី៖ ថ្នាក់ទី៧ ។

សុជា៖ នៅសាលាណា?

ធី៖ នៅសាលាបឋមសិក្សាកោះខែល ។

សុជា៖ វត្តណឹង?

ធី៖ បាទ ។

សុជា៖ ចុះក្រោយមកទៀត?

ធី៖ ខ្ញុំបានទៅរៀននៅកោះកុង ។

សុជា៖ ទៅរៀននៅណឹងទៀត?

ធី៖ បាទ ដល់ពេលប្រឡង ។

សុជាៈ កាលណឹងពូទៅនៅកោះកុងឆ្នាំណា?

ធីៈ ឆ្នាំ៦៣,៦៤ ។

សុជាៈ ពូទៅរៀននៅណឹងដល់ថ្នាក់ទីប៉ុន្មានដែរ?

ធីៈ រៀនដល់ថ្នាក់ទីបី ប្រឡងឌីប្លូមប្រឡងឌីប្លូមជាប់បានមករៀននៅជម្ពូវ័ន្ត នៅភ្នំពេញ ។

សុជាៈ កាលណឹងរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ធីៈ អាណឹងរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

សុជាៈ រៀនដល់ថ្នាក់ទីប៉ុន្មាន?

ធីៈ ថ្នាក់ទី៧ ។

សុជាៈ អាណឹងបាក់អងហើយមើលទៅ?

ធីៈ តែអត់ទាន់បានប្រឡងទេ ។

សុជាៈ ឆ្នាំណាពូដែររៀនណឹង?

ធីៈ ឆ្នាំចូល៦៩ជិតរដ្ឋប្រហារណឹងបានគេបិទសាលាណឹង ហើយខ្ញុំត្រឡប់មកផ្ទះវិញ ។

សុជាៈ អីចឹងដល់ឆ្នាំ៧០ណឹងពូត្រឡប់មកផ្ទះវិញ?

ធីៈ បាទ ។

សុជាៈ ចុះក្រោយពូត្រឡប់មកផ្ទះវិញពូទៅណាទៀត?

ធីៈ ខ្ញុំនៅផ្ទះណឹងរហូតដល់ឆ្នាំ៧១, ៧១ចូលធ្វើឈ្លបឃុំគេណឹង ។

សុជាៈ កាលណឹងមូលហេតុអីបានពូចូល?

ធីៈ កាលណឹងកងទ័ព ព្ទសូរសម្តេចប្រកាសតាមវិទ្យុ សម្តេចអំពាវនាវឲ្យចូលព្រៃម៉ាគីដើម្បីរំដោះប្រទេស ឲ្យចេញផុតពីរបបលន់ នល់ហើយបានចូលចលនាបដិវត្តន៍ណឹងមក ។

សុជាៈ កាលណឹងពូចាំពូចូលក្នុងឆ្នាំ៧១ ពូចូលក្នុងខែណា?

ធីៈ ក្នុងខែប្រាំបី ។

សុជាៈ ថ្ងៃណាពូចាំទេ?

ធីៈ ភ្លេចហើយ បើមើលនៅក្នុងប្រវត្តិរូបខ្ញុំបានដឹង ។

សុជាៈ កាលចូលណឹងពូគ្រាន់តែស្តាប់ព្ទតាម សេចក្តីអំពាវនាវរបស់សម្តេចសីហនុ រឺមានភូមិឃុំគេមកត១គ្នាទៀត?

ធីៈ កាលណឹងសម្តេចសីហនុបានអំពាវនាវ បានភូមិ-ឃុំបានអំពាវនាវ ។

សុជាៈ កាលពូចូលដំបូងណឹង ពូអាយុប៉ុន្មាន?

ធីៈ អាយុ១៩ឆ្នាំ ។

សុជាៈ ចុះបើគិតមកដល់ឥឡូវពូអាយុប៉ុន្មានហើយ?

ធីៈ អាយុ៥២ឆ្នាំហើយ ។

សុជាៈ ហើយចូលដំបូងពូចូលជាឈ្លបភូមិទេ?

ធីៈ អត់ទេឈ្លបឃុំ ។

សុជាៈ អាណឹងទីតាំងគេនៅកន្លែងណា?

ធីៈ ទីតាំងគេនៅសាលាឃុំ ទឹកវិល ។

សុជាៈ នៅទឹកវិលទេ?

ធីៈ អត់ទេនៅឃុំកោះខែល តែនៅខាងនោះជិតវត្តទឹកវិល ។

សុជាៈ អីចឹងពូនៅឆ្នាំ៧១នេះ បានន័យថានៅក្នុងទឹកដីស្រុកស្អាងនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពីណាដែរ?

ធីៈ កាលណឹងគេហៅតំបន់រំដោះហើយ ។

សុជាៈ កាលណឹងស្អាងណឹងនៅក្នុងតំបន់រំដោះណឹងតាំងពីឆ្នាំណាដែរ?

ធីៈ គ្រាន់តែលន់ នល់នេះភ្លាមស្អាងរំដោះរហូត ។

សុជាៈ រំដោះភ្លាមតាំងពី៧០មក?

ធីៈ ទេមិនមែន៧០ទេខែ១, ខែ២អីចឹងទៅរំដោះហើយ ព្រោះគ្រាន់ថាយើងផ្ទុះសង្គ្រាមភ្លាម ទ័ពគេវៃចូលមកហើយ ។

សុជាៈ កាលណឹងខាងណាវៃចូល?

ធីៈ កាលណឹងមានទ័ពវៀតណាម-ពួកធាវគី ។

សុជាៈ ទ័ពវៀតណាមណឹងវៃចូលពីក្រោមមកវិញ?

ធីៈ បាទ ។

សុជាៈ តែម៉ាដុំនេះគ្មាននៅក្រោមការគ្រប់គ្រងរបស់លន់ នល់ទៀតទេ?

ធីៈ បាទអត់ ។

សុជាៈ កាលណឹងមានពីណាផ្សេងទៀតក្មេងៗដំណាលពូអីចូលទៅដែរ?

ធីៈ ចូលទៅនៅក្នុងភូមិ កាលខ្ញុំទៅណឹងមិនទាន់មានទេ ។

សុជាៈ ចុះឪពុកម្តាយរបស់ពូអីគាត់គិតយ៉ាងម៉េចដែរ?

ធីៈ កាលខ្ញុំមកណឹងឪពុកខ្ញុំស្លាប់ហើយ ម្តាយខ្ញុំណឹងកូនចៅគេហៅទៅនៅភ្នំពេញអស់ហើយ ។

សុជាៈ ចុះពូនៅក្នុងភូមិនេះប៉ុន្មាននាក់?

ធីៈ ខ្ញុំនៅតែម្នាក់ខ្ញុំទេ ។

សុជាៈ តែម្នាក់ពូទេ អីចឹងបងប្អូនទាំងអស់គេទៅនៅភ្នំពេញអស់?

ធីៈ បាទ! នៅភ្នំពេញទាំងអស់ ។

សុជាៈ កាលណឹងពូមានគ្រួសារនៅ?

ធីៈ នៅទេ គ្រួសារខ្ញុំទើបការក្រោយនេះទេ ខ្ញុំនៅទីនេះខ្ញុំជាជាងអីចឹងឪពុកក៏គាត់ស្លាប់ ខ្ញុំសុខចិត្តនៅមើលទ្រព្យសម្បត្តិដីធ្លីផ្ទះសម្បែងចេះតែនៅទៅ ។

សុជាៈ កាលណឹងឪពុកពូស្លាប់ដោយសារអីដែរ?

ធីៈ គាត់ឈឺតាំងពីសង្គម ។

សុជាៈ គាត់ស្លាប់មុនរដ្ឋប្រហារឬក្រោយរដ្ឋប្រហារ?

ធីៈ មុនរដ្ឋប្រហារ តែវាក្បែរៗគ្នាណឹង ។

សុជាៈ ចុះក្រោយមកពូទៅណានៅពេលទៅធ្វើការនៅឈ្លបភូមិណឹង?

ធីៈ ក្រោយមកគេ មិនដឹងឆ្នាំណាពិតប្រាកដទៀត ។

យ៉ាងៈ ធ្វើឈ្លបឃុំណឹងបានរយៈពេលប៉ុន្មានខែ?

ធីៈ បានម៉ាឆ្នាំជាង ។

សុជាៈ ការងារឈ្លបឃុំណឹងគេឲ្យធ្វើយ៉ាងម៉េច?

ធីៈ គេឲ្យយាមតាមឃុំណឹង ដល់ពេលបានម៉ាឆ្នាំ គេរើសទ័ពគេចាប់រើសគេឲ្យបញ្ជូនតាមឃុំទៅបញ្ចូលក្នុងទ័ព ។

សុជាៈ ចូលទៅដល់ណា?

ធី: កាលណឹងគេរើសដំបូងនៅកោះធំឯណោះ គេបញ្ជូនទៅជាអង្គភាពតែម្តងដូចថាម៉ាឃុំគេយកប៉ុន្មាននាក់ទៅយើងចូលទៅទ័ព កាលចូលទៅដំបូងខ្ញុំនៅក្នុងអនុសេនាធំ២៣ គេបញ្ជូនទៅមុនដំបូងគេចាត់តាំងនៅក្នុងអនុសេនាធំ២៣ វរៈ១១២ ។

សុជា: ពីណាគេប្រធានអនុសេនាធំណឹង?

ធី: ប្រធានអនុសេនាធំណឹង ម៉ាលី ។

សុជា: ប្រុសទេ?

ធី: ប្រុស ។

សុជា: ចុះប្រធានវរសេនាតូច?

ធី: តាណាត ។

សុជា: កាលណឹងតាណាតណឹងប្រធានវរសេនាតូចលេខប៉ុន្មានដែរ?

ធី: ១១២ ។

សុជា: ចុះលើតាណាតណឹងទៀត?

ធី: លើតាណាតមានតែ... ដឹងច្បាស់ដល់ទៅភូមិភាគឯណោះ ព្រោះវាស្រពិចស្រពិល ព្រោះវាកាលណឹងគេធំជាង យើងនៅឯនេះយើងអត់ដឹងទេ គេចាត់តាំងសុទ្ធតែលាក់ការណ៍កាលណឹងគេលាក់ការណ៍ ។

សុជា: កាលណឹងនៅកន្លែងណាមូល?

ធី: មូលដ្ឋានដូចថានៅស្រុកកោះ តែវាមិននៅម៉ាកន្លែងទេបីថ្ងៃនៅនេះ បីថ្ងៃនោះ ផ្លាស់ទៅនេះទៅនោះ ព្រោះខ្លាចពួកយន្តហោះវៃ ។

សុជា: ម៉ាលីណឹងស្រុកកំណើតនៅឯណា?

ធី: នៅកោះធំ ។

សុជា: កាលណឹងទ័ពណឹងជាទ័ពស្រុក ឬទ័ពតំបន់?

ធី: ទ័ពស្រួច ។

ឃាង: ពួម៉ាអនុសេនាធំមានប៉ុន្មាននាក់?

ធី: មានជាង១០០ ។

សុជា: ចុះពេលដែរលទៅធ្វើទ័ពនៅណឹងគេមានឲ្យយើងធ្វើអីខ្លះ?

ធី៖ អត់ទេគេឲ្យយើងហាត់រៀន យុទ្ធសាស្ត្រវ៉ៃហើយពេលយូរៗមានការអីគេឡើងទៅវៃម្តង ។

សុជា៖ កាលណឹងពូមានឋានៈអីដែរ ឬនៅជាយុទ្ធជន?

ធី៖ នៅជាយុទ្ធជនធម្មតានៅឡើយទេ ។

សុជា៖ ចុះពេលដែរនៅណឹងនៅបានប៉ុន្មានខែ ប៉ុន្មានឆ្នាំដែរ?

ធី៖ នៅទ័ពណឹងនៅរហូត មកដល់វៃដល់ពេលវ៉ៃឡើយវ៉ៃទៅពេលចុះៗមកវិញមក អាណឹងស្រេចបញ្ជគេឲ្យវ៉ៃ ហើយដល់ឆ្នាំ៧៣ទ័ពខ្ញុំគេផ្លាស់ទៅលិចវិញហើយ ។

សុជា៖ ណឹងនៅក្រោមបញ្ជារបស់ណាគដែរ?

ធី៖ អាណឹងគាត់នៅបញ្ជារហូតណឹង ។

សុជា៖ ចល័តទៅខាងណាដែរ?

ធី៖ ទៅតំបន់១៥កណ្តាលស៊ឹង ។

សុជា៖ កាលណឹងទៅវ៉ៃពីខាងណាមកវិញ?

ធី៖ កាលណឹងទៅវ៉ៃនៅដីក្រហម ។

សុជា៖ ក្បាលថ្នល់ដីក្រហមណឹង?

ធី៖ ក្បាលថ្នល់ដីក្រហមណឹង ម៉ាជួរសៀមរាប និយាយទៅម៉ាជួរផ្លូវជាតិលេខ ប៉ុន្តែយើងបែកម៉ាកំណាត់ ម៉ាកំណាត់ភាគខាងនិរតី ហើយចាប់ពីឃុំកន្ទោរ ឃ្លាំមឿងអីណឹងឡើយមកលើអាណឹងក្រវ៉ាត់ក្រុង វ៉ានៅភូមិភាគពិសេស ។

សុជា៖ អីចឹងពូនិយាយអំបាញ់មិញថាផ្លូវជាតិលេខ២ពីត្រឹមនោះទៅសម្រាប់និរតី ចុះខាងផ្លូវជាតិ២មកត្រឹមនេះគេហៅអីគេ?

ធី៖ អាណឹងគេហៅភូមិភាគពិសេស ។

សុជា៖ អីចឹងណាគអីណឹងគេហៅភូមិភាគពិសេសវិញ?

ធី៖ បាទ ។

សុជា៖ ព្រោះខ្ញុំឆ្ងល់ដែរ ព្រោះស្អាង កោះធំយើងនៅចន្លោះភូមិភាគនិរតី និងបូព៌ាអីចឹងពូ តែខ្ញុំអត់ដឹងថាអាណឹងគេហៅថាភូមិភាគអីខ្ញុំមិនមែនដឹងពូ?

ធី៖ កាលណឹងភូមិភាគពិសេស ។

សុជា៖ កាលណឹងដឹកនាំដោយពីណាគេទៅ?

ធីៈ កាលណឹងដឹកនាំដោយ វ៉ន វេត ។

សុជាៈ ពូមានដឹងថាវ៉ន វេតណឹងស្រុកកំណើតនៅខាងណាដែរ?

ធីៈ ខ្ញុំអត់ដឹងទេអាណឹងពួកគេធំៗគេខ្ពស់ ។

សុជាៈ អីចឹងវ៉ន វ៉េត ណឹងគាត់លើណាតណឹងទៀត?

ធីៈ បាទ ។

សុជាៈ ចុះបន្ទាប់ពីវ៉ន វ៉េតណឹងមក?

ធីៈ ខ្ញុំមិនបានដឹងច្បាស់ទេពុគេថានៅភូមិភាគណឹង យើងពុវាមិនច្បាស់ទេប៉ុន្តែដឹងថាទ័ពលើ តាណាត ណឹង តាណាតជាមួយតាពីនអនុ ។

សុជាៈ ពូធ្លាប់ពុឈ្មោះប្រាក់ទេ?

ធីៈ អត់ដែរពុទេ ។

សុជាៈ ព្រោះខ្ញុំសម្ភាសន៍នៅលើនេះមានឈ្មោះមុី ប្រាក់មួយ ហើយមុីប្រាក់ណឹងប្រហែលជា ក្រោយមកក្លាយជាគណៈស្រុកកោះធំ តែដល់ពេលបែក៧៥ឡើងទៅលើគាត់ឡើងទៅ ជាមួយតាណាតអីដែរតើ?

ធីៈ បែកអីគេ?

សុជាៈ បែក៧៥?

ធីៈ ខ្ញុំ?

សុជាៈ អត់ទេនិយាយប្រាក់ណឹង?

ធីៈ ព្រោះបើនិយាយឲ្យខ្ញីទៅកងទ័ពដល់ចាប់ពី៧៣ទៅ វាចាប់ច្រើនទៅហើយ ព្រោះអីកាល មុនវរៈសេនាតូចវាចាប់ពី៣០០ ដល់ចាប់ពី៧៣ទៅវាឡើងជាងម៉ឺននាក់ នៅក្នុងកងទ័ព តាណាត ។

សុជាៈ កងទ័ពតាណាតណឹង?

ធីៈ បាទ ដូច្នេះយើងមិនដឹងពីណាពីណីខ្លះទេច្រើន គ្រាន់តែខ្ញុំនិយាយគ្រាន់តែម៉ាឆ្នាំ៧៣ណឹង អនុសេនាធំចាំមិនអស់ផង ព្រោះទ័ពវាច្រើនពេក កាលមុនគេរៀបតែបីអនុសេនាធំទេដល់ កម្លាំងវាត្រូវការច្រើន វាឡើងដល់៨អនុសេនាតូច ម៉ាអនុសេនាធំកម្លាំងច្រើនណាស់ ។

សុជាៈ ចុះកាលណឹងចេញជាកងពលហើយរឺនៅ?

ធី៖ កងពលនៅទេ ដល់៧៣ទើបឡើងវរសេនាធំទេ ។

សុជា៖ ចុះកាលណឹងប៉ុន្មានវរសេនាតូច បានម៉ាវរសេនាធំទៅ?

ធី៖ បីវរសេនាតូច ។

សុជា៖ ហើយម៉ាវរសេនាតូចណឹងគ្នាប៉ុន្មាននាក់?

ធី៖ ជាង៣០០ ។

សុជា៖ អីចឹងនៅក្នុងភូមិភាគពិសេសណឹងមានប៉ុន្មានវរសេនាតូចទៅ?

ធី៖ អត់ដឹងទេ ខ្ញុំដឹងកងវរសេនាធំកាលមុនដំបូងបង្កើតភ្លាម បន្ទាប់ពីវរសេនាតូចបានម៉ាវរសេនាធំ មានតែម៉ាវរសេនាធំទេ វរសេនាធំណឹងបានតែជាង៧ទេ ជាង៧ណឹងវាចំរុះពី១១២, ១១៦, ១១៧កាលណឹងគេយកចុងៗ ១១២គេយក២ទៅ ១១៦គេយក៦ទៅ ១១៧គេយក៧ទៅ... ។

សុជា៖ ចុះចាប់ពី៧៣មក?

ធី៖ ៧៣វាបានពីរវរសេនាធំ វរសេនាធំ៦៧,៦៨ទៀត ។

សុជា៖ កាលជំនាន់ណឹងមុនយើងឡើងវៃអីគេឲ្យយើងហាត់រៀនក្បួនយុទ្ធសាស្ត្រទេ?

ធី៖ អត់ទេវៃអត់មានកំណត់ថ្ងៃទេ ស៊ីសងគេបញ្ជាមកពីលើទេ កងស៊ើបការណ៍គេដឹងកន្លែងណាគេទៅវៃតែម្ដង តែរឿងហាត់រាល់ថ្ងៃតែម្ដង ។

សុជា៖ ចុះកាលណឹងការហាត់ការបង្រៀនអីពីណាគេអ្នកបង្រៀនទៅ?

ធី៖ កាលណឹងមានតែមេក្រុមគេណឹង មេក្រុមគេរៀនពីអនុសេនាតូចមក អនុសេនាតូចគេរៀនពីអនុសេនាធំ អនុសេនាធំគេទៅពីណាៗមកយើងអត់ដឹងទេតៗគ្នាមក ។

សុជា៖ កាលនៅក្នុងពេលហាត់ក្បួនវៃអីចឹងមានបង្ហាត់បង្រៀនផ្នែកនយោបាយដែរ?

ធី៖ នយោបាយមិនសូវជាប៉ុន្មានទេ ព្រោះអត់សូវមានកន្លែងបង្រៀន ទាហានច្រើនរកកន្លែងដាក់សាលាឯណាបាន គ្រាន់តែប្រជុំអីតាមក្រុមអីមាន តែបើបង្រៀននយោបាយអីធំដុំអីអត់មាន គេខ្លាចយន្តហោះខ្លាចអី ។

សុជា៖ ចុះពេលជំនាន់ណឹងពូធ្លាប់ឡើងទៅសមរភូមិខាងណាដែរ?

ធី៖ ខ្ញុំកាលនៅទ័ពស្រួច៧១, ៧២អាណឹងទៅខាងព្រែកជ័រណឹង ស្វាយរលំ ប៉ុន្តែយើងអត់វៃចំពោះទ័ពគេអត់វៃបន្ទាយទេ គេស្កាត់តែកម្លាំងដែរជំនួយមក ហើយបន្ទាយណឹងទ័ពតំបន់គេអ្នកវៃ ។

សុជា៖ កាលណឹងនៅយើងនេះនៅតំបន់ប៉ុន្មានណាដែរ?

ធី៖ ប៉ុន្តែយើងនេះមិនមែនរបស់ទ័ពស្រួចរបស់តំបន់ទេ គឺរបស់ភូមិភាគតែម្តង តែតំបន់គេសហការណ៍ជាមួយ អានេះតំបន់២៥យើងនៅក្នុងតំបន់២៥ភូមិភាគពិសេស ។

សុជា៖ ពេលឡើងវៃម្តងៗអារម្មណ៍របស់ពូយ៉ាងម៉េច ដូចពេលវៃមុនដំបូងអី?

ធី៖ អានេះបើនិយាយពីអារម្មណ៍វិញវាទៅជាធម្មតាទៅហើយ ព្រោះមនុស្សយើងនៅទ័ពតែគេបញ្ចូឲ្យវៃមិនដឹងជាអាណីអាណាទេចេះតែទៅហើយ ហើយអត់គិតរឿងឈឺអីទេ ចុះក្មេង ១៨, ១៩, ២០ ទៅតាមគេចេះតែទៅហើយ គេយ៉ាងម៉េចឯងម៉េចចេះតែទៅតាមគេហើយ ។

សុជា៖ ពូទៅវៃម្តងៗមានដែរកន្លែងណាឈ្នះ កន្លែងណាចាញ់ទេ?

ធី៖ អារឿងវៃនេះយើងមិនយកឈ្នះចាញ់ទេ គេហៅសង្រ្គាមឈ្លបគេវៃបន្តិចៗ អានេះជាការរំខាន ចុះមានកម្លាំង មានអាវុធណាសម្បូរបែបឯណា ។

សុជា៖ ពូមានដែរបាក់ទ័ពអីដែរ?

ធី៖ បាក់ទ័ពមានច្រើនកន្លែងណាស់ បាក់ទ័ពការទៅផ្លូវជាតិលេខ២ក៏មានបាក់ម្តងដែរ អាណឹងទ័ពធំប៉ុន្តែគេវៃស្កាត់ចេញពីក្បាលថ្នល់ដីក្រហមមកស្ពានបាក់នេះ ដល់នេះគេដឹងយើងទៅគេចាំមុន កាលបាក់ម៉ាសារណឹងស្លាប់ច្រើនណាស់ បាក់ទ័ពស្លាប់ច្រើនណាស់ ។

សុជា៖ កាលនៅពេលណឹងប្រធានក្រុមពូឈ្មោះ?

ធី៖ ប្រធានក្រុមនៅណឹង?

សុជា៖ បាទ?

ធី៖ វាភ្លេចទៅ ស្លាប់បាត់យូរហើយ ។

សុជា៖ ចុះប្រធានកងហា?

ធី៖ ប្រធានកងហា ឈ្មោះសុខ តាចេវ ។

សុជា៖ តាចេវណឹងនៅឯណាស្រុកកំណើតគាត់?

ធី៖ បែបនៅកោះធំនោះ ។

សុជា៖ ខ្ញុំធ្លាប់មានប្រវត្តិរូបរបស់ចេវណឹងដែរ ខ្ញុំធ្លាប់ទៅដល់ផ្ទះ គាត់ឈ្មោះចាវ ចេវ?

ធី៖ អត់ដឹងទេ ភ្លេចអស់ហើយ បើចូលមកដល់ឥឡូវចូល៣០ឆ្នាំហើយ ។

សុជា៖ គាត់ណឹងនៅពោធិ៍បាន ចេវណឹង សព្វថ្ងៃនៅសល់តែបងស្រីគាត់ទេ ។

ធី៖ ចាវណឹងស្លាប់ហើយមើលទៅ?

សុជា៖ ណឹងហើយបាត់ខ្លួន?

ធី៖ ស្លាប់ហើយកាលសង្គ្រាម ហើយបើបងសុខនោះស្មុងការកងហាខ្ញុំក៏ស្លាប់ដែរ ពេលវៃនៅសៀមរាម ។

សុជា៖ ចុះពេលក្រោយ៧៣ពូមានដកទៅកន្លែងណាទៀតដែរ?

ធី៖ ដល់ឆ្នាំ៧៣ខ្ញុំវៃកាលណឹងវៃនៅសិត្បូ វៃនៅសិត្បូខ្ញុំរបួសម៉ាសារទៅ ។

សុជា៖ របួសត្រូវកន្លែងណាដែរ?

ធី៖ ខ្ញុំត្រូវដៃ ។

សុជា៖ ទាល់តែពេលត្រូវរបួសគេឲ្យមកដេកពេទ្យដែរ?

ធី៖ គេឲ្យមកដេកពេទ្យ ។

សុជា៖ ដេកពេទ្យនៅកន្លែងណាកាលណឹង?

ធី៖ ដេកពេទ្យ កាលមុនក្រាំងយ៉ូវពេទ្យភូមិភាគ ។

សុជា៖ ដេកពេទ្យណឹងពូបានសម្រាកប្រហែលប៉ុន្មានទៅ?

ធី៖ អត់ទេខ្ញុំមក ចង់ជាម៉ាខែឯនោះ ។

សុជា៖ ក្រោយមកគេឲ្យឡើងទៅឯណាទៀត?

ធី៖ ក្រោយមកគេទៅវៃនៅសៀមរាប ។

សុជា៖ សៀមរាប ម៉ាសារទៀត?

ធី៖ នៅឯណោះវៃជាប់គ្នារហូតអត់មានថ្ងៃឈប់ទេ ចាប់ពី៧៣ទៅយើងអត់មាននៅក្រោយទេ នៅមុខរហូត អត់មានដកមកក្រោយទេ ខ្សែត្រៀមគេនៅមុខណឹងតែម្តង ។

សុជា៖ ចុះកាលណឹងអត់មានដូរកងទេ?

ធី៖ កាលណឹងផ្លាស់ប្តូរអស់ហើយ ប្តូរនៅកង ។

សុជាៈ កាលណឹងឡើងដល់កងពលហើយរឺនៅ?

ធីៈ កាលណឹងកងពលខ្ញុំមិនប្រាកដទេ ដល់មានកងពល១១ ទើបមានកងពល១២ បានឡើងកងពល ។

សុជាៈ អីចឹងកងពល១១, ១២ណឹងមានតាំងពីឆ្នាំណាមកដែរ?

ធីៈ មិនច្បាស់ទេ ។

សុជាៈ តែប្រហែលជា៧៣, ៧៤អីណឹងពូ?

ធីៈ បើមិន៧៣, ៧៤ ។

សុជាៈ ចុះពីណាគេប្រធានកងពល១១?

ធីៈ ភ្លេចទៅហើយគេនៅតំបន់១៥ អានេះតំបន់២៥ ។

សុជាៈ កាលណឹងពេលគេបង្កើតកងពលទៅ ពូនៅក្នុងកងពល១១ ឬ១២?

ធីៈ ខ្ញុំនៅក្នុងកងពល១២ដដែលណឹង ។

សុជាៈ ហើយពីណាគេប្រធានកងពល១២ណឹង?

ធីៈ តាណាត ។

សុជាៈ ចុះដល់ពេលក្រោយមកទៀត ពេលឆ្នាំ៧៥?

ធីៈ ៧៥តាណាតនៅតែប្រធានកងពលណឹង ។

សុជាៈ ចុះដល់ពេលហៀបបែកទីក្រុងភ្នំពេញឆ្នាំ៧៥ណឹង ពូឈរជើងនៅកន្លែងណាដែរ?

ធីៈ នៅខាងត្បូងភ្នំពេញណឹង តែខ្ញុំវាតាំងពីខ្ញុំវៃសៀមរាបមកខ្ញុំត្រូវរបួស ត្រូវរបួសម៉ាសារទៀតកាលណឹងសន្លប់ គេថាស្លាប់ហើយសន្លប់៣យប់ បីថ្ងៃកាលណឹងត្រូវយន្តហោះវៃដល់ហើយគេឲ្យខ្ញុំធ្វើពេទ្យម្តង ពេទ្យណឹងពេទ្យប្រចាំកងណឹងទេ ។

សុជាៈ ពេលនៅកងពល១២ណឹងដែរ?

ធីៈ អត់នៅកង២៣ ព្រោះប្រវត្តិរូបបើនិយាយទៅវាយ៉ាប់ដែរ ព្រោះអីនៅនេះអត់បានឡើងអីតាំងពីនៅទីនេះរហូត នៅតែអានុក្រុម យុទ្ធជន ឡើងបានមេក្រុមណឹងអស់ហើយព្រោះគេថាខ្ញុំពាក់ព័ន្ធបងប្អូនបង្កើតនៅក្នុងតំបន់ខ្មាំង ហើយខ្ញុំកាលណឹងមានបានដឹងអី គេឲ្យរាយការណ៍តាមត្រង់ចេះតែរាយការណ៍តាមត្រង់អីចឹងទៅ ហើយដល់យើងវណ្ណៈភាពក៏ខុសទៀតយើងវាអ្នករៀនខ្ពស់ក៏ខុសវណ្ណៈគេដែរ ដូច្នេះអាតួនាទីដឹកនាំយើងអត់មានទេ ។

សុជាៈ ចុះពេលជិតបែកទីក្រុងភ្នំពេញអីចឹងពូមានបានឡើងសមរភូមិទេ រឺនៅសមរភូមិណាដែរ?

ធីៈ ខ្ញុំនៅសមរភូមិ បើនិយាយឲ្យចំទៅ៧៣ ខ្ញុំទៅវ៉ៃសៀមរាបរបួសខ្ញុំធ្វើពេទ្យដល់ពេទ្យណឹង រហូតដល់យូរទៅខ្ញុំវាខ្សោយអារឿងវ៉ៃណឹង នៅពេទ្យណឹងគ្រាប់ផ្លោងមកវាសន្កត់យូរទៅខ្ញុំ ធ្លាក់ឈាមធ្លាក់អីទៅ ក្រោយមកគេដកខ្ញុំឲ្យនៅមន្ទីរ មន្ទីរអនុសេនាធំ ២៣របស់វរសេនាតូច១១៧ នៅមន្ទីរវិញគេអត់ឲ្យទៅវៃទេ។

សុជាៈ នៅណឹងគេឲ្យធ្វើអ្វី?

ធីៈ នៅមន្ទីរណឹងគេឲ្យរាយការណ៍ចំនួនយុទ្ធជនមានប៉ុន្មាន គ្រាប់មានប៉ុន្មានអីប៉ុន្មាន។

សុជាៈ ចុះដល់ឆ្នាំ៧៥ ជិតចូលទីក្រុងភ្នំពេញណឹង?

ធីៈ ដល់ចូលទីក្រុងភ្នំពេញហើយគេដកខ្ញុំមកនៅទ័ពវិញ៧៥ ។

សុជាៈ តែវ៉ៃបានទីក្រុងភ្នំពេញរឺនៅ?

ធីៈ វ៉ៃដកទ័ពមកនៅព្រៃសណឹង ។

សុជាៈ តែពេលគេវ៉ៃចូលទីក្រុងភ្នំពេញឆ្នាំ៧៥ណឹង ពូចូលទីក្រុងភ្នំពេញពូចូលតាមផ្លូវណា?

ធីៈ ទៅតាមតាខ្មៅ ។

សុជាៈ ទៅតាមតាខ្មៅ?

ធីៈ នេះទៅតាមទួលក្រសាំងឡើងទៅតាមតាខ្មៅ ។

សុជាៈ ពេលឡើងទៅដល់គេឲ្យពូនៅឯណា?

ធីៈ ខ្ញុំអ្នកមន្ទីរគេឲ្យដើរតាមទ័ពរហូតកងរយ ។

សុជាៈ កាលណឹងកងពលកងនេះគេឲ្យឈរជើងនៅម៉ាដុំណាដែរ?

ធីៈ នៅទួលក្រសាំងទៅតាមតាខ្មៅណឹង ។

សុជាៈ ណឹងហើយពេលបានជ័យជំនះហើយ?

ធីៈ ពេលបានជ័យជំនះគេនៅភ្នំពេញបានប្រហែលជាម៉ាខែដែរ ។

សុជាៈ នៅកន្លែងណាកាលណឹង?

ធីៈ នៅភ្នំពេញខ្ញុំនៅម៉ាដុំផ្សារថ្មី ។

សុជាៈ គេឲ្យធ្វើអីគេនៅផ្សារថ្មីណឹង?

ធី៖ គេឲ្យនៅសម្អាតទីក្រុង ព្រោះវាអត់មាននេះគេយកទ័ពទៅសម្អាតទីក្រុងតាមផ្ទះថ្ម ឬ សម្រាមអី ។

សុជា៖ កាលណឹងនៅក្នុងកងពល?

ធី៖ ១៧ ។

សុជា៖ ក្រោមបញ្ជារបស់តាណាគេ ណឹងដែរ?

ធី៖ បាទ ។

សុជា៖ ពូខ្ញុំធ្លាប់សម្ភាសន៍គេពីមុនមក ពេលដែរតំបន់ភូមិភាគចូលទៅមួយៗគេឲ្យនៅកន្លែងផ្សេងៗគ្នា គេមិនឲ្យនៅកន្លែងតាមួយទេ?

ធី៖ គេអត់ឲ្យនៅកន្លែងតែមួយទេ ព្រោះភូមិភាគផ្សេងវាអត់មានសិទ្ធិចូលទីក្រុងភ្នំពេញទេ មានតែភូមិភាគពិសេសទេ ព្រោះភ្នំពេញវារបស់ភូមិភាគពិសេស គេយកក្រវ៉ាត់ក្រុង បើនិយាយភូមិភាគគេមួយៗគេសុទ្ធតែរាប់ខេត្ត តែអានេះភូមិភាគមួយគេយកតែម៉ាភ្នំពេញណឹងវាសំខាន់នៅខេត្តកណ្ដាល ។

សុជា៖ ចុះដល់ពេលក្រោយមកទៀត?

ធី៖ ក្រោយមកទៀតខ្ញុំនៅភ្នំពេញបានម៉ាខែ គេឲ្យមកនៅទ័ពវិញ ។

សុជា៖ ទ័ព?

ធី៖ ដូចនៅកាន់ក្នុងមន្ទីរ ដល់ពេលមន្ទីរវាអស់អីធ្វើគេឲ្យមកនៅទ័ពវិញ ទៅនៅជួយសម្អាត គេមកណឹងធ្វើជាអនុក្រុមទេ ហើយបើនិយាយពីតួនាទីគេអ្នកតស៊ូជាមួយគ្នាគេមានតួនាទីគេខ្ពស់ហើយ តែបើនិយាយពីប្រវត្តិរូបយើងវាទៅអត់រួច ។

សុជា៖ កាលណឹងពូថាគេដកពីមន្ទីរ គេដកពីមន្ទីរណាមក?

ធី៖ មន្ទីររបស់១១៧ ។

សុជា៖ ចុះដកមក?

ធី៖ អាណឹង១១៧ដដែល តែអានុសេនាធំ៧៣ ។

សុជា៖ ហើយណឹងទីតាំងគេនៅឯណាដែរ?

ធី៖ នៅក្បែផ្សារថ្មី ។

សុជា៖ ចុះក្រោយពីណឹងមក?

ធី: ក្រោយមកដល់ចូលទ័ពមក ទ័ពណឹងគេឲ្យមកនៅធ្វើស្រែនៅព្រៃសនេះ ។

សុជា: នៅក្នុងឆ្នាំណា?

ធី: នៅឆ្នាំ៧៥ ។

សុជា: ខែណាពូចាំទេ?

ធី: ទេមិនចាំទេ ម៉ាណឹងមកនៅណឹងរហូតនៅព្រៃសណឹង ។

សុជា: មកនៅណឹងដល់ពេលណាដែរ?

ធី: នៅរហូតដល់ពេលគេហៅខ្ញុំទៅធ្វើការនៅកន្លែងស-២១ណឹង ។

សុជា: នៅបានប៉ុន្មានខែនៅព្រៃសណឹង?

ធី: យូរខែដែរ ខ្ទង់៥, ៦ខែ ។

សុជា: ពូធ្វើអីដែរនៅព្រៃសណឹង?

ធី: នៅធ្វើស្រែដឹកដី ដឹកអី នៅកន្លែងស្រូវណឹង ទ័ពម៉ានៅណឹងទាំងអស់ទ័ព១១២ណឹងធ្វើស្រូវ ។

សុជា: ពេលណឹងមិត្តភ័ក្ររបស់ពូធ្វើទ័ពណឹង នៅព្រៃសណឹងមានគ្នាប៉ុន្មាននាក់ដែរ?

ធី: នៅព្រៃសណឹងម៉ាវរៈសេនាតូច មានគ្នាជាង៣០០នាក់ ។

សុជា: ចុះពេលណាដែរគេដកពីព្រៃសទៅស-២១?

ធី: ស-២១ណឹងដល់ពេល ខ្ញុំវាអត់ដឹងរឿងស-២១ទេ ដល់ពេលតាឃឿនវរសេនាធំ ហ៊ុយយើងមិនហឹម ហ៊ុយនេះទេ ហ៊ុយមួយទៀតកាលណឹងខ្ញុំនៅជាមួយគាត់រហូត ព្រោះខ្ញុំនៅមន្ទីរនៅជាមួយគាត់ដែរ គាត់គេចាត់តាំងមកធ្វើកន្លែងស-២១ គេចាត់តាំហឲ្យមកមុនយូរហើយហ៊ំណឹងគេប្រធានវរសេនាធំ២៦៧ គេមកធ្វើការនៅ ហើយតាណាតគាត់ដល់ពេលនេះមកគាត់មកកាន់ខាងសេនាធិការ ។

សុជា: ណាតណឹងឡើងសេនាធិការផង?

ធី: គាត់កាន់ខាងសេនាធិការ គាត់ទទួលខាងស-២១ផង តាណាត ។

សុជា: ហើយគេឲ្យមកណឹងនៅក្នុងឆ្នាំណា?

ធី: ចូល១៩៧៦ហើយ ។

សុជា: មកដល់ស-២១មុនដំបូងពូបានឃើញអីមុនគេ?

ធី៖ ខ្ញុំអត់ដឹងថាគេយកមកធ្វើនៅណឹង ព្រោះពីយើងថាចាត់តាំងយើងទៅណា ហ៊ណឹងបានមកយកខ្ញុំណឹងគេខ្ញុំនៅណឹង ហើយគេបានឲ្យខ្ញុំធ្វើបញ្ជី ។

សុជា៖ ពូបានស្គាល់ហ៊ណឹងពីមុនមកដែរ?

ធី៖ ហ៊ណឹងពីមុនគេអនុសេនាធំ២១ ខ្ញុំនៅ២៣តែគេប្រធានអនុសេនាធំតែខ្ញុំយុទ្ធជននៅ អនុសេនាធំ២៣នេះទេ ។

សុជា៖ ចុះម៉េញពូនិយាយថាហ៊ុយ?

ធី៖ ហ៊ុយ បាយខ្ញុំនៅជាមួយ ហ៊ុយគេនៅវរៈ១១២ ។

សុជា៖ ចុះហ៊ុយ ណឹងគាត់មានរាងរៅយ៉ាងម៉េចដែរ?

ធី៖ ហ៊ុយណឹងគាត់រាងខ្ពស់ខ្មៅ មាឌធំ ។

សុជា៖ ចុះដល់ពេលគេយកពូមកព្រៃសណឹងហ៊ុយណឹងមកតាមគេ?

ធី៖ គាត់នៅក្នុងគណៈស-២១ហ៊ុយ ។

សុជា៖ ចុះពេលមកដល់ស-២១ ពីណាគេប្រធានទៅ?

ធី៖ កាលមុនមានតែណាតទេ ក្រោយមកតាណាតបានគេដកទៅ បានមកតាឌុចនេះ ។

សុជា៖ តាណាតណឹងនៅបានរយៈពេលប៉ុន្មាន?

ធី៖ នៅប្រហែលមិនបានមួយឆ្នាំផង នៅបានប៉ុន្មានខែណឹងការងារ ព្រោះការងារគាត់ដូចថាវាអត់បច្ចេកទេសក៏គាត់ខាងទាហាន ។

សុជា៖ ចុះឌុចណឹងទៅជាប្រធានស-២១នៅក្នុងឆ្នាំណា?

ធី៖ តាំងពីដូរតាណាតទៅគាត់ឡើងមកឌុច ។

សុជា៖ អីចឹងបានន័យថាពូទៅស-២១ មុនឌុចណឹងមកគ្រប់គ្រងណឹងទៀត?

ធី៖ បាទ ។

សុជា៖ អីណឹងនៅក្នុង៧៦ដែរ ឬក្រោយមក?

ធី៖ ៧៦ ។

សុជា៖ ហើយពូមានដឹងថាឌុចណឹងមកពីខាងណាដែរ?

ធី៖ ឌុចណឹងខ្ញុំអត់ស្គាល់ទេ មិនដឹងមកពីខាងណាទេអានេះស្រេចតែពីខាងលើគេចាត់តាំងមកធ្វើណឹងតែម្តង ។

សុជាៈ ឌុចណឹងមានរាងរ៉េយ៉ាងដែរ?

ធីៈ ឌុចណឹងស្គម ។

សុជាៈ មុខមាត់គាត់យ៉ាងម៉េចដែរ?

ធីៈ ស្រួច ស ។

សុជាៈ តូចរឺធំ?

ធីៈ តូចទេ ។

សុជាៈ ចុះពេលនៅក្នុងស-២១មកក្រោយមកមានទៅណាទៀតទេ?

ធីៈ អត់ទេ ។

សុជាៈ មុនណឹងកើតចេញជាគុកស-២១ណឹងកាលណឹងគេមានគុក ដូចពូថាអីចឹងនៅជិតផ្សារថ្មី ដល់ខាងវាចង្អៀតទៅ?

ធីៈ អត់ចង្អៀតទេ មុនដំបូងនៅនោះប៉ុន្តែដល់មកៗទាំងអស់តែម្ដង អត់មានពីរទេ ។

សុជាៈ ថីបានមក?

ធីៈ ព្រោះថាកន្លែង គេយកកន្លែងគេធ្វើកាតព្រោះអានោះវាកណ្ដាលក្រុងមិនដឹងដែនការខាងលើគេយ៉ាងម៉េច គោលបំណងគេយ៉ាងម៉េចបានផ្លាស់ពីណឹងមកនេះទេ ។

សុជាៈ ពូដែលឮឈ្មោះគុកដាំផេងទេ?

ធីៈ អត់ដែរទេ ។

សុជាៈ ចុះពូនិយាយមិញថាវាមានបី ហ៊ុយស្រែនោះមួយ ហើយចាន់និងឌុចនោះគ្គាប់ខាងសួរចម្លើយ ហើយហ៊ីនោះខាងការពារ ចុះកាលណឹងមានកងចាប់ចងទេ?

ធីៈ កាលណឹងកងចាប់ចងអីមានតែខាងកងការពារ ព្រោះហ៊ុយ ហើយណឹងទទួលខាងអ្នកទោសអ្នកអីណឹង ។

សុជាៈ ចុះឧទាហរណ៍ដល់ពេលទៅចាប់អ្នកទោស អ្នកទោសច្រើនគេចាប់ពីខាងណាមក?

ធីៈ ខ្ញុំមិនសូវដឹងច្បាស់ទេ ។

សុជាៈ អាណឹងច្រើនពីណាគេអ្នកទៅចាប់?

ធីៈ អាណឹងច្រើនតែហ៊ី, ហ៊ីប្រធានខ្ញុំគេចាត់តាំងកម្លាំងទាំងកងការពារយើង ។

សុជាៈ អីចឹងពួកពូនៅខាងការពារ អីចឹងនៅខាងការពារណឹងគេចែកជាប៉ុន្មានផ្នែកទៀត?

ធី:	ការពារណើងមានតែយាមអ្នកទោសណើង ។

សុជា: ហើយអ្នកទៅចាប់?

ធី:	អ្នកទៅចាប់ និងអ្នកយាមអ្នកទោសណើង ។

សុជា: ហើយពូអ្នកកាន់បញ្ជីណើងនៅក្នុង?

ធី:	នៅកងការពារដែរ ។

សុជា: អ្នកកាន់បញ្ជីណើងមានប៉ុន្មាននាក់នៅក្នុងណើង?

ធី:	ខ្ញុំណើង មានតែម្នាក់ណើង ហើយគ្រាន់តែគេផ្ទេរអ្នកទោសចូលមក ប្រវត្តិរូបអ្នកទោសចូលមកហើយពេលគេដកអ្នកទោសចេញទៅវិញឲ្យដឹងចំនួនទៅ ។

ឃ៉ាង: ពេលដែលពូទទួលបានបញ្ជីពីហ៊ាណើងថាត្រូវអ្នកទោសចេញប៉ុន្មាននាក់ៗ តើពូបញ្ជីទៅឲ្យពីណាផ្សេងធ្វើ ឬពូធ្វើម្នាក់ឯង?

ធី:	អាណើងខ្ញុំគ្រាន់តែចុះលេខបន្ទប់អីចឹង គ្មានពីណាធ្វើអត់ជងខ្ញុំធ្វើតែម្នាក់ខ្ញុំទេ ។

ឃ៉ាង: ហើយចុះអ្នកទោសដែលត្រូវបញ្ជូនចេញអីចឹងមានគេ?

ធី:	ណើងហើយដល់នេះមានកងការពារណើង ដល់ពេលនេះគេមកយកហើយតាមបញ្ជីគេចេញទៅ ។

សុជា: អាណើងចំណារអីធំត្រឹមណា?

ធី:	ចំណារមកពីឌុចណើង និងហ៊ាណើង ហ៊ាណើងជាអ្នកទទួលពីឌុចមក ។

សុជា: ចុះបញ្ជីចូល?

ធី:	អាណើងដល់ពេលគេយកមក គេយកមកគ្រប់ទូទាំងប្រទេសមិនដឹងជាតាមណាតាមណីតែយើងទទួលពេលគេដឹកមក មកហើយចូលមកតាមខេត្តតាមតំបន់ ។

សុជា: ចុះដល់ពេលគេសួរចម្លើយគេឲ្យអ្នកកាន់បញ្ជីទៅចូលជិតទេ?

ធី:	អត់ទេ អាណើងការងារផ្សេងទេ គ្រាន់តែយើងដើរ ធ្លាប់និយាយគ្នា ស៊ីបាយក៏ខុសគ្នាដែរ ការពារនៅក្រុមណាគឺនៅក្រុមណើង ហើយនៅសួរចម្លើយនៅក្រុមគេផ្សេង យើងអត់សិទ្ធិទៅដើរ ទៅជិតអ្នកទោសគេអត់មានទេ មែនទែនគេអត់ឲ្យដឹងទេ ។

សុជា: កន្លែងគុកទួលស្លែងណើងការដាក់អ្នកទោសគេមានបែងចែកប្រភេទអ្នកទោសទេ?

ធី៖ អានេះស៊ីសងថាគេយកមក ថាឌុច, ហ៊ាណឹងគេឃើញឈ្មោះណាធំអីចឹងគេដាក់បន្ទប់ដាច់ដោយឡែកពីគ្នាទៅ ហើយបើថាអ្នកណាមិនសំខាន់អីគេដាក់បន្ទប់ចូលគ្នាបន្ទប់ច្រើនទៅ ។

សុជា៖ ពូកាលណឹងមានដឹងថាអគារខាងណាគេដាក់អ្នកទោសរបៀបម៉េចទេ ៗ?

ធី៖ អត់ទេរឿងអគារគេអត់គិតសំខាន់គេដាក់ក្នុងបន្ទប់តូចមួយតែម្តង ។

សុជា៖ ចុះអ្នកមានឋានៈធំអាណឹងគេដាក់បន្ទប់ណាដាច់ពីអ្នកផ្សេង?

ធី៖ គេដាក់បន្ទប់មួយៗតែឯង ។

សុជា៖ ចុះអាអ្នកដាច់បន្ទប់រួមគ្នាអ្នកខ្លះមានបន្ទប់រួមគ្នាច្រើនណាស់អាណឹង?

ធី៖ ច្រើនគ្រួសារគ្រូរអីកម្មកររោងចក្រអីណឹងតួនាទីមេក្រុមអនុក្រុមអីវ៉ាន់ណឹងតួនាទីតូចតាច ។

សុជា៖ អីចឹងកាលចាប់អ្នកទោសមុនដំបូង ប្រភេទអ្នកទោសចាប់ពី៧៦អីទៅអាណឹងច្រើន ប្រភេទអ្នកទោសយ៉ាងម៉េច ។

ធី៖ កាលខ្ញុំទៅធ្វើមុនដំបូងអ្នកទោសណឹងច្រើនអ្នកទោស១៧មេសាទេ ពួករោងចក្ររោងអីប៉ុន្តែកាលណឹងអ្នកទោសមកមានដោះលែងទៅស្រែ ទៅបញ្ជូនចុះ បញ្ជូនឡើងអីចឹងវាអត់មានការសម្លាប់ទេ ដល់ក្រោយមករឿងអ្នកទោសកម្មករកម្មអីអត់សូវមានទេ ច្រើនរឿងផ្ទៃក្នុងតែម្តងគុក ។

សុជា៖ ផ្ទៃក្នុងយ៉ាងម៉េចទៅពូ?

ធី៖ ច្រើនផ្ទៃក្នុងទ័ពក្នុងតំបន់ ក្នុងភូមិភាគអ្នកធ្វើការក្នុងជួរបដិវត្តន៍ ។

សុជា៖ ហេតុអីបានគេចាប់ពួកគាត់មក?

ធី៖ មិនដឹងជាមូលហេតុអីទេ ខ្ញុំរកនឹកវាមិនឃើញអារឿងមូលហេតុចាប់ ដូចថាគ្នាអត់ទាំងដឹងអីផងចេះតែចាប់តាមខ្សែតាមអីចឹងមក ។

សុជា៖ ពូអ្នកកាន់បញ្ជីអ្នកទោសពូមានចាំបានថាអ្នកទោសថ្នាក់លដឹកនាំធំៗណាមួយទេ?

ធី៖ ថ្នាក់ដឹកនាំធំៗ ព្រោះអាធំពួកភូមិភាគ តំបន់គេអត់ឲ្យខ្ញុំសរសេរទេគេគ្រាន់តែដឹងតែចំនួនគេដាក់ដោយឡែកហើយ ។

សុជា៖ អីចឹងបញ្ជីថ្នាក់ភូមិភាគ តំបន់អីគេមានបញ្ជីគេដាក់ផ្សេងទៀតអ្នកទោសណឹង?

ធី៖ បាទ គេអត់ឲ្យយើងទៅសរសេរផ្ទាល់បើសិនគេមានឈ្មោះក៏គេហុចឈ្មោះឲ្យមកយើងដែរហើយយើងសរសេរទៅកត់ទៅ ។

សុជាៈ ចុះកាលណឹងដូចជាហ៊ួ យន់, ហ៊ួ នឹមអីពូមានបាន?

ធីៈ ខ្ញុំអត់មានបានចុះទេ ។

សុជាៈ មើលពូអាចនិយាយបានថាឈ្មោះអ្នកធំមួយណាដែរពូបានសរសេរ?

ធីៈ ខ្ញុំអត់មានបានសរសេរទេ ព្រោះអ្នកធំគេយកមកគេចូលកន្លែងគេផ្សេងហើយ ។

សុជាៈ ឌុចជាអ្នកទទួលខុសត្រូវផ្ទាល់ហើយ?

ធីៈ ណឹងហើយ ឌុច, ចាន់, ប៉ុនគេដឹងហើយ គេមិនឲ្យយើងដឹងទេ ព្រោះគេខ្លាចបែកការណ៍ ។

សុជាៈ ពូមិញនិយាយឈ្មោះប៉ុន មួយទៀត?

ធីៈ ប៉ុនណឹងក៏នៅក្នុងស្ទួរចម្លើយដែរ ។

សុជាៈ ប៉ុនណឹងមានឈ្មោះអីមួយទៀតទេ?

ធីៈ ដូចអត់មានទេ ។

សុជាៈ ហើយគាត់មកពីខាងណា?

ធីៈ មកជាមួយឌុច ជាមួយចាន់ណឹង ។

សុជាៈ ប៉ុនណឹងមានរាងរៅយ៉ាងម៉េចដែរ?

ធីៈ ទាបដែរ ។

សុជាៈ ស រឺ ខ្មៅ?

ធីៈ ទេអត់សប៉ុន្មានទេ ខ្មៅក៏មិនខ្មៅដែរសណ្តែកបាយ ។

សុជាៈ គាត់រាងរៅគាត់យ៉ាងម៉េចដែរ ចរិកលក្ខណៈរបស់គាត់?

ធីៈ ខ្ញុំដឹងមិនច្បាស់អានេះគាត់ខាងស្ទួរចម្លើយ ។

សុជាៈ គាត់ណឹងនៅខាងស្ទួរចម្លើយ?

ធីៈ បាទ ។

សុជាៈ នៅស-២១ណឹងក្រៅពីការផាររពូចុះបញ្ជីណឹងពូមានធ្វើអីផ្សេងទៀតទេ?

ធីៈ ខ្ញុំអត់មានទេ មានតែការផាររណឹងមួយធ្វើមិនទាំងទាន់ផង?

សុជាៈ ហើយធ្វើតែម្នាក់ឯងណឹង?

ធីៈ បាទ ហើយក្រោយមកដល់ឆ្នាំ៧៨ បានគេឲ្យកុមារមួយទៅជួយយកឈ្មោះអ្នកទោសដឹងបន្ទប់ដឹងអីបានជួយប៉ុន្មានដែរ ។

សុជាៈ ឈ្មោះអីគេ?

ធីៈ ឈ្មោះឡាន់ តែមិនដឹងអីឡាន់ ។

សុជាៈ អាយុប៉ុន្មានដែរ?

ធីៈ អាយុជាង១០ឆ្នាំណឹង ។

សុជាៈ ហេតុអីបានគេហៅក្មេងណឹងទៅជួយការងារ?

ធីៈ ព្រោះអីការងារណឹងវាច្រើន វាដូចថាសរសេរវាអត់ទាន់ ហើយយើងសរសេរផង ហើយយើងត្រូវទៅកត់ឈ្មោះលេខបន្ទប់អ្នកទោសដើម្បីចុះក្នុងបញ្ជីណឹងផង អីចឹងយើងអាល័យតែសរសេរផង យើងដើរទៅផងវាពិបាក ។

សុជាៈ ចុះកាលណឹងហេតុអីបានជាគេមិនយកមនុស្សពេញវ័យទៅធ្វើ គេយកក្មេងទៅធ្វើវិញ?

ធីៈ មិនដឹងទេរឿងការចាត់តាំងរឿងការងារគេ ។

សុជាៈ ឈ្មោះឡាន់ ជនជាតិអី ឬខ្មែរយើងទេ?

ធីៈ ខ្មែរយើងទេ ។

សុជាៈ គេយកមកពីណា?

ធីៈ អាណឹងតែពួក កាលមុនពួក៧០៣ទេដល់គេចាប់៧០៣ចង់អស់ទៅ ។

សុជាៈ ក្រោយមកគេចាប់ពួក៧០៣ណឹង?

ធីៈ គេចាប់ចង់អស់នៅអ្នកធ្វើការក្នុងគុកណឹង បានខុចគេយកមកពួកពីអមលាំងនោះមក ។

សុជាៈ អោ ឡាន់ណឹងពួកអមលាំង?

ធីៈ បាទ ។

សុជាៈ ពូមានដឹងថាហេតុអីកាលណឹងបានគេចាប់ពួក៧០៣ទេ?

ធីៈ មិនដឹងកាលណឹងវាច្របូកច្របល់ណាស់មិនដឹងជាស្អីៗទេ ។

សុជាៈ គេចាប់ខ្លាំងនៅឆ្នាំណាពួក៧០៣ណឹង?

ធីៈ ៧៧ហើយ ។

សុជាៈ ចុះតាណាតមានត្រូវបានគេចាប់ទេ?

ធីៈ តាណាតក្រោយមកក៏ត្រូវបានគេចាប់ តែខ្ញុំអត់បានទៅកៀកផ្ទាល់ទេព្រោះអាណឹងគេចូលអគារគេផ្សេង គ្រាន់តែដឹងតែគេអត់ឲ្យយើងចូលទេ ។

សុជាៈ តែណាគណើងត្រូវបានគេចាប់ដាក់ទួលស្លែងណើងដែរ?

ធីៈ ខ្ញុំមើលក្នុងបញ្ជីឈ្មោះឃើញមាន ។

សុជាៈ ពូនិយាយមុនដំបូងថាភូមិភាគពិសេសណើងដឹកនាំដោយវ៉ន វេ៉តអ៊ីចឹងក្រោយមកណើង វ៉ន វេ៉តណើងទៅណាក្រោយពេលគេចាប់ណាគណើង?

ធីៈ វ៉ន វេ៉តណើងមកដឹងយ៉ាងម៉េចទេសង្ស័យតែគេចាប់ដែរ ។

សុជាៈ ពូអត់ដែរដឹងរឿងណើងទេ?

ធីៈ ថ្នាក់ខ្ពស់ណាស់ ថ្នាក់ខ្ពស់ជាងខ្ញុំ ។

សុជាៈ តែវ៉ន វេ៉តណើងពីមានដឹងថាបាត់ខ្លួន រឺចាប់យកទៅដាក់នៅទួលស្លែងអីដែរពូមានដឹងទេ?

ធីៈ ខ្ញុំសង្ស័យតែចាប់ ព្រោះតែចាប់តាណាគ ទាល់តែចាប់វ៉ន វេ៉តហើយបានមានចាប់តាណាគមានចាប់ពីលើមកបានចាប់ពីក្រោមជាប់ ដូចយើងចាប់អនុសេនាធំទាល់តែចាប់អនុសេនាតូចតាមខ្សែអ៊ីចឹង ។

សុជាៈ ចុះពូអត់ដឹងពីមូលហេតុចាប់វ៉ន វេ៉តណើងទេ?

ធីៈ ខ្ញុំរាល់ថ្ងៃចេះតែឆ្ងល់មនុស្សចាប់បញ្ជូនមក ហើយសុទ្ធតែមនុស្សជួនណាខ្ញុំជួបអ្នកធ្វើទ័ពជាមួយខ្ញុំពីរនាក់ សុទ្ធតែអ្នកស្រឡាញ់គ្នាដល់ឃើញ ខ្ញុំអត់ហានមើលមុខផងអាណោចអធមអត់ហាននិយាយអីមើលឃើញ ហើយសុទ្ធតែធ្លាប់កំសត់កម្រជាមួយគ្នានៅសមរភូមិ ។

សុជាៈ អ្នកធ្លាប់ជាអតីតទាហានជាមួយគ្នានៅក្នុងកងពល៧០៣ណើង?

ធីៈ បាទ ។

សុជាៈ ក្រោយមកគេចាប់ដាក់ក្នុងទួលស្លែងណើងដែរ?

ធីៈ ហើយដូចអ្នកនៅធ្វើការនៅស-២១គេចាប់ មិនដឹងជារឿងស្អីខ្លះគ្រាន់តែយាមដេកលក់ណើងងក់ក៏មានរឿង ខ្លះនេះអីណើងក៏គេចាប់... ។

សុជាៈ ពូមានដឹងរឿងរបស់ហ៊ូ នឹមដែរគេចាប់ដាក់នៅស-២១ ណើងដែរ?

ធីៈ ប៉ុន្តែគេចូលកន្លែងបន្ទប់គេផ្សេងទៅ ។

សុជាៈ ចុះកាលណើងមានល្បីថាហ៊ូ នឹមណើងស្លាប់ក្នុងគុកទេ?

ធីៈ មានតែយកទៅសម្លាប់ទេ រឿងតែចូលស-២១ហើយអត់មានរស់ទេ លើកលែងតែរួចតែម្តង អត់រួចនៅហើយ ។

សុជាៈ អីចឹងនៅក្នុងគុកទួលស្លែងណឹងពូមានដែរឃើញអ្នកដឹកនាំធំអីគេដើរទៅមើលគុកមើលអីទេ?

ធីៈ គុកទួលស្លែងអត់មានទេ ។

សុជាៈ អត់ដែរទេ? ចុះមានភ្ញៀវបរទេសចូលទៅមើលដែរ?

ធីៈ អត់ទេកន្លែងណឹងបើតាមខ្ញុំដឹង ប៉ុន្តែក្រែងគេចូលមកខ្ញុំមិនដឹងព្រោះអីខ្ញុំនៅខាងក្នុង ខាងក្រៅខ្ញុំអត់ដឹងទេ ខ្ញុំនៅតែខាងក្នុង ខាងក្រៅខ្ញុំអត់ដឹង ព្រោះខ្ញុំនៅក្នុងរបងគុកណឹងហើយ ព្រោះដេក នៅណឹងសរសេរនៅណឹងគេមិនឲ្យចេញទេ ព្រោះអ្នកទោសមកចេញចូលៗ ផ្ទាល់ អត់ឃើងសរសេរម្នាក់ណឹង ។

សុជាៈ ចុះអ្នកទោសខបមាអ្នកទោសចូលមកពេលយប់ពូត្រូវតែទៅ?

ធីៈ អត់ទេខ្ញុំនៅដេកនៅណឹង នៅកន្លែងខ្ញុំធ្វើការណឹង ។

យ៉ាងៈ ចុះពូធ្វើការនៅស-២១ណឹងដែរ មានដែរឌុចកោះហៅប្រជុំគ្នា?

ធីៈ អាណឹងមានតែទៅរៀន មានតែទៅរៀននៅកន្លែងអគ្គភាព នៅកន្លែងឌុចណឹង ។

សុជាៈ ពូធ្លាប់ទៅដែរ?

ធីៈ ទៅទាំងអស់គ្នាណឹង ទាំងកងសួរចម្លើយ ទាំងកងការពារណឹង គេទៅប្រជុំទៅរៀនសូត្រនយោបាយម៉ាឆ្នាំម្តង រឺក៏បីខែម៉ាដងយើងត្រូវទៅប្រជុំទាំងអស់គ្នា ។

យ៉ាងៈ គេរៀនណឹងមានតែរៀននយោបាយតែមួយមុខទេ?

ធីៈ ទេអាណឹងបើរៀនបច្ចេកទេសរៀនតាមបច្ចេកទេសផ្សេងគ្នាទេ បើគេប្រជុំរាល់ថ្ងៃខាងសួរគេធ្វើការរាល់ថ្ងៃទៅ ការពារ ការពាររាល់ថ្ងៃទៅ ។

សុជាៈ ពូនៅស-២១ណឹងមានដែររៀននយោបាយផ្សេងក្រៅពីជាមួយឌុចណឹងទេ?

ធីៈ អត់ទេ ។

សុជាៈ ដូចជាមួយសុន សេនណឹង?

ធីៈ អេ៎ា កាលណឹងដូចនេះគេមកម្តង ។

សុជាៈ ពីណាគេ?

ធីៈ ពីណាទេដូចសុន សេន មកខទ្ទេសនាមម្តង កាលណឹងទាំងអស់គ្នា ។

សុជាៈ ឆ្នាំណាដែរ?

ធីៈ ភ្លេចហើយអត់ប្រាកដ ទាល់តែសួរអ្នកដែរនៅធ្វើការណឹងទាំងអស់គ្នា ។

សុជាៈ សុន សេនកាលណឹងពូដឹងថាមានឋានៈអីដែរ?

ធីៈ កាលណឹងគាត់បញ្ជាការទ័ពភូមិភាគពិសេសយើងណឹង ។

សុជាៈ ហើយគាត់មកនៅក្នុងឆ្នាំណាពូ?

ធីៈ អត់ប្រាកដទេអាណឹង ភ្លេចហើយយូរណាស់ហើយកាលណឹង ។

សុជាៈ គាត់មកនិយាយរឿងអីខ្លះទៅ?

ធីៈ និយាយពីរឿងនយោបាយធម្មតា ។

សុជាៈ នយោបាយគេនិយាយពីស្អីគេ?

ធីៈ បំពាក់បំប៉នរឿងនយោបាយ ឲ្យយើងខំធ្វើការតាមផ្នែកតាមអីណឹង ។

សុជាៈ ចុះក្រៅពីសុន សេនពូមានស្គាល់មេដឹកនាំធំខ្មែរក្រហមទេកាលណឹង?

ធីៈ សុន សេននេះមកណឹងមិនស្គាល់ច្បាស់ផងកាលណឹងតាមមើលមកម្តង មករៀនតែមួយថ្ងៃ មកបើកវគ្គមួយថ្ងៃណឹង ។

សុជាៈ ចុះពូកាលណឹងគេមដែរឲ្យទៅធ្វើមេទ្វិញនៅស្តាតទេ?

ធីៈ ចាំអត់ច្បាស់ទៀត ។

សុជាៈ ចុះពូធ្លាប់ស្គាល់ខៀវ សំផន, ប៉ុល ពត, អៀង សារីអីដែរ?

ធីៈ អត់ដែរ?

សុជាៈ ចុះដែរឮឈ្មោះគេដែរ?

ធីៈ ប៉ុល ពត, ខៀវ សំផន, អៀង សារីក៏ដែរឮឈ្មោះដែរ ។

សុជាៈ កាលណឹងឮឈ្មោះប៉ុល ពតណឹងមានឈ្មោះថាអីដែរ?

ធីៈ ថាជានាយករដ្ឋមន្ត្រី ។

សុជាៈ ចុះអៀង សារី?

ធីៈ អៀង សារី ឧបនាយករដ្ឋមន្ត្រី ។

សុជាៈ ចុះខៀវ សំផន?

ធីៈ ខៀវ សំផន ថាប្រធានរដ្ឋ អានេះថាតាមវិទ្យុប្រកាសផ្សាយ ។

សុជាៈ តាមគេប្រកាសណឹង?

ធីៈ បាទ ។

សុជាៈ ចុះពូពុះអីចឹងៗ នៅក្នុងឆ្នាំណាដែរ?

ធីៈ អាណឹង តាំងពីបែក៧៥មក ។

សុជាៈ ពូនិយាយម៉េច គេមានបញ្ជូនឲ្យទៅធ្វើការជាមួយពូដែរកាលណឹង ឈ្មោះអីគេ ឈ្មោះឡាន់?

ធីៈ ឈ្មោះឡាន់ ។

សុជាៈ អាណឹងអ្នកជួយរត់បញ្ជី?

ធីៈ បើតាមពិតទៅអាណឹងគោលបំណងគេ បើតាមខ្ញុំដឹងគោលបំណងគេបម្រុងដកខ្ញុំ គេចង់បញ្ចូលបញ្ជៀតដើម្បីដក ប៉ុន្តែក្មេងវាធ្វើការមានធ្វើអីចេញ ហើយវាចូលណឹងក៏ក្តាប់មិនសូវណែនព្រោះឯកសារវាច្រើនមក ហើយធ្វើការបើនិយាយទៅកាលណឹងដូចអត់មានមនុស្សធ្វើការអីចឹងដូចឆ្ងល់ អាណាការងារសរសេរៗចង់ងាប់ ហើយសរសេរណឹងអត់បានសរុបណឹង សរុបអត់ទាន់ផងបើការងារវាដេញជាប់រហូតណឹង ។

សុជាៈ នៅក្នុងឆ្នាំណាដែរឡាន់ណឹងមកជួយការងារ?

ធីៈ ប្រហែល៧៧, ៧៨ហើយកាលណឹង ។

ឃាងៈ ឡាន់ណឹងពេលមកជួយធ្វើការងារពូណឹង ជួយធ្វើអីខ្លះ?

ធីៈ ជួយសរសេរឈ្មោះផង ជួយយកក្រដាស់លេខបន្ទប់អ្នកទោសអីណឹង ។

សុជាៈ ក្មេងណឹងមានលក្ខណៈយ៉ាងម៉េចដែរបានគេឲ្យមកធ្វើការ?

ធីៈ គេចេះអក្សរខ្លះៗដែរ គេមកពីខាងអមលាំង មកពីអមលាំងគេទុកចិត្តជាងពួកភូមិភាគពិសេស ឥឡូវអ្នកយាមមកពីអមលាំងណឹងគេចង់ជម្រុះអស់ហើយ ៧០៣វាអស់មនុស្សហើយ ។

សុជាៈ ខ្ញុំចង់សួរពូបន្តិចនៅក្នុងបរិវេណដែរពូធ្វើការណឹង ពូដែរឃើញគេធ្វើទារុណកម្ម ឬក៏សម្លាប់មនុស្សដែរ?

ធីៈ នៅកន្លែងខ្ញុំក្នុងគុកណឹងអត់មានទេ ព្រោះគេសួរចម្លើយគេយកទៅក្រៅទាំងអស់ គេដើរនាំយកផ្ទះក្រៅៗ នោះទាំងអស់នៅជុំវិញគុក ។

សុជាៈ ចុះគេអត់សួរនៅក្នុងគុកទេ?

ធីៈ សួរយ៉ាងម៉េចកើតនៅគុកមនុស្ស អ្នកទោសម៉ាគំនរសួរអី ។

សុជាៈ សួរអាផ្ទះនៅជុំវិញណឹង?

ធីៈ ទេ ឆ្ងាយដែរមិនមែនជិតគុកទេ ។

សុជាៈ ចុះពូដែរឮសំឡេងអ្នកទោសស្រែកទេ?

ធីៈ អ្នកទោសស្រែក វាយើងមិននេះទេ ពេលធ្វើការជួនណាគេយកសួរណឹង ឮតែវាមិនសួរ ចាប់អារម្មណ៍រឿងការងាររគេ ។

សុជាៈ ពូនិយាយមិញនិយាយថាឌុចធ្លាប់បានទៅសួរចម្លើយផ្ទាល់ខ្លួន?

ធីៈ ឌុចអត់ទេម៉ាក្នុងគុកនេះ បើគេសួរក៏គេនៅក្រៅដែរ ។

សុជាៈ តែឌុច សួរផ្ទាល់រឹមានពីណាសួរដែរ?

ធីៈ យីគេសុទ្ធតែមានអង្គភាពគេសួរចម្លើយតែម្តង ។

សុជាៈ ពូធ្លាប់ឮសួរឈ្មោះទុយទេ?

ធីៈ ទុយ ធ្លាប់ឮសួដែរប៉ុន្តែអាណឹងគេខាងសួរចម្លើយ ។

សុជាៈ ចុះអ្នកទោសថ្នាក់ធំៗអី ថ្នាក់កងពល ថ្នាក់ភូមិភាគអីបើសួសចម្លើយពីណាគេអ្នកសួរទៅ?

ធីៈ អាណឹងស៊ីសង ឌុចណឹងអ្នកចាត់តាំងទេ ។

សុជាៈ ចុះអ្នកទោសពេលគេដល់ម៉ោង ដល់ពេលគេយកចេញទៅគេយកទៅខាងណាទៅ?

ធីៈ ចេញទៅយ៉ាំងម៉េចទៅ?

សុជាៈ ឧបមាថាគេសួរចម្លើយអស់ហើយ ហើយត្រូវគេចេញយកទៅកម្ទេចអីចឹងគេយកទៅខាង ណាទៅ?

ធីៈ អាណឹងគេដឹកចេញទៅក្រៅ ។

សុជាៈ គេអត់ធ្វើនៅក្នុងណឹងទេ?

ធីៈ ណឹង តែនេះគេដាក់ឡានយកចេញហើយ ។

សុជាៈ ក្នុងអ្នកទោសមួយគេសួរចម្លើយប៉ុន្មានដងបានគេយកទៅ?

ធីៈ មិនដឹងទេបច្ចេកទេសគេ ស៊ីសងគេសួរបានចេញឬមិនចេញ ។

សុជាៈ អីចឹងអ្នកសួរនឹងក្រែងមានអ្នកកត់នៅក្នុងណឹង អ្នកកត់ត្រា?

ធីៈ គេសួរអ្នកសួរចម្លើយណឹងគេអ្នកធ្វើខ្លួនគេ ហើយគេរាយការណ៍ទៅកងសួរចម្លើយគេ ។

សុជាៈ យើងដឹងតែបញ្ជីទៅ?

ធី៖ យើងដឹងតែពីការងារយើង គ្មានទៅពាក់ព័ន្ធ ។

សុជា៖ តាំងពីពូធ្វើការមកដល់ឆ្នាំ១៩៧៩ ពូអាចប៉ាន់ស្មានថាចំនួនអ្នកទោសប៉ុន្មាននាក់ដែរ?

ធី៖ អត់ដែរសរុបផង សូម្បីតែចូលប្រចាំថ្ងៃក៏អត់ដឹង ខ្ញុំដូចបងធីគាត់និយាយអីចឹងគាត់ថាប៉ុន្មានស្មាន ខ្ញុំស្មានចេះតែថាទៅវាក៏មិនប្រាកដប្រាជាអីដែរ យើងសំខាន់បញ្ជីមាននៅទាំងអស់ ឯកសារមាននៅទាំងអស់ទេតើវាអត់បញ្ហាយើងអាចសរុបដឹងទេតើ ហើយចេះតែនិយាយប៉ុណ្ណេះៗ ខ្ញុំចង់ថាម៉ឺនប៉ុន្មានពាន់ ពីពាន់ក៏បាន ម៉ឺនយក៏បានម៉ឺនហាសិបនាក់វាអត់ប្រាកដទេ ដូច្នេះបើយើងអត់មានឯកសារយើងចេះតែថាទៅ ។

សុជា៖ កាលជិតទាន់ណឹងពូមានដែរសុំគេមកលេងផ្ទះទេ?

ធី៖ អត់មានច្បាប់ទេ គ្រាន់តែដើរចេញពីកន្លែងក៏អត់បានដែរ យើងនៅកន្លែងណានៅណឹងដឹងតែពីធ្វើការចូលកន្លែងយើង ។

សុជា៖ ចុះពូមានដែរផ្តល់ដំណឹងអីមកអ្នកផ្ទះទេ?

ធី៖ ផ្តល់ណឹងវាអត់មានឲ្យចេញមកក្រៅបន្តិចផងណឹង ។

សុជា៖ សួរដំណឹងផ្តល់ដំណឹងក៏មិនដែរ?

ធី៖ អត់មានទេ មានឯណាតែអ្នកណានៅណានៅណឹងហើយការងារ ។

សុជា៖ កាលពូចុះឈ្មោះមានដែរប៉ះឈ្មោះបរទេសដែរ?

ធី៖ បរទេសខ្ញុំវាចង់ភ្លេចហើយកាលណឹង ដូចមានមកពីកំពង់សោម ។

សុជា៖ មានច្រើនជនជាតិទេពូ?

ធី៖ អត់ទេបរទេសអាពួកមកពីបរទេសពួកអាមកអឺរ៉ុប អាពួកមកពីអាមេរិកមិនសូវមានប៉ុន្មានទេ ។

សុជា៖ តែមានដែរ?

ធី៖ មានដែរ?

សុជា៖ ចុះវៀតណាម?

ធី៖ វៀតណាមក៏មានដែរ វៀតណាមច្រើនតែពួករត់ទៅតាមកំពង់សោម រត់ទៅថៃ ។

សុជា៖ អីចឹងពូបានឃើញអ្នកទោសជនជាតិណឹងទេ ជនបរទេសណឹងទេ?

ធី៖ ឃើញច្រើនតែវៀតណាម ។

សុជាៈ ពេលដែលពូធ្វើការនៅទួលស្លែង តាមយោបល់ពូ តាមគំនិតពូ មានឃើញអ្វីដែរពូគិតប្លែកខុសពីធម្មតាទេ?

ធីៈ អានេះការងារបើនិយាយទៅធ្វើតាមការចាត់របស់គេ អាប្លែកមិនប្លែកវាមិនគិតទេធ្វើម៉េចធ្វើទៅឲ្យមានទាន់ការងារតែប៉ុណ្ណឹង បើយើងធ្វើមិនច្បាស់មិននេះគេនិយាយហើយតើបើយើងធ្វើបញ្ជីអ្នកទោសឈរក្រៅ តែប្រទ្បំប្លុក៏អីណឹងយើងអ្នកទទួលជិនួសហើយវាម៉ត់ចត់សំខាន់ពេលយកចេញយកចូលនឹងពិតប្រាកដហើយ ។

សុជាៈ ពូមានដែរខុសទេ?

ធីៈ ខ្ញុំខ្លាចណាស់ ។

សុជាៈ ពូមានដែរច្រឡំ រឺខុសអីទេ?

ធីៈ អត់ទេ ព្រោះខ្ញុំខ្លាចខ្ញុំធ្វើ ព្រោះគេយកចេញមកដល់ខាងមុខនេះក៏ខ្ញុំពិនិត្យម្តងទៀតដែរខ្ញុំពិនិត្យឲ្យផ្ទាល់ទៀតកុំឲ្យវាច្រឡំ ព្រោះតែម្នាក់ឯងបើមានពីរនាក់នៅជួយទៅមានអី កាលណឹងចេះតែទាន់ហើយ ។

សុជាៈ អីចឹងដល់ពេលអ្នកទោសចេញទៅយើងទៅពិនិត្យមើលអ្នកទោសនៅថ្ងៃណា អីពិប្រាកដមែនឬ?

ធីៈ មានអ្នកហៅតាមឈ្មោះណឹងពិតប្រាកដតាមបញ្ជីណឹងទៀតបានគេយកចេញបាន ។

សុជាៈ ការធ្វើអីចឹង ពូដែរប៉ះ ចុះដូចអ្នកទោសធំៗយើងទៅពិនិត្យអីចឹងដែរ?

ធីៈ អត់ទេបើអ្នកធំគេយកទៅគេដឹងបោះគេ ។

សុជាៈ ចុះជនបរទេស?

ធីៈ ជនបរទេសក៏អត់ប៉ះពាល់ដែរ គេដឹងជនបរទេសមានតែប៉ុន្មាននាក់ណឹង ។

សុជាៈ ចុះពួកណឹងពូមានដឹងថាគេយកទៅកម្ទេចនៅកន្លែងណាដែរ?

ធីៈ អត់ដឹងពិតប្រាកដទេ ដឹងតែគេដឹកឡានយកចេញទៅ ។

សុជាៈ ចុះឡានដឹកចេញ ដឹកចូលណឹងមានរាងយ៉ាងម៉េចដែរ?

ធីៈ ឡាន ឡានចិនណឹង អាកាត់ៗចិនណឹង ។

សុជាៈ ឡានណឹងគេខ្ទប់ជិត ឬក៏ចំហរ?

ធីៈ គេគ្របជិតទាំងអស់ ។

សុជា៖ មានប៉ុន្មានឡានដែរ?

ធី៖ មានឡានពីរ ឡានបីណឹង ។

សុជា៖ ចុះម៉ាឡានៗដាក់បានប៉ុន្មានទៅ?

ធី៖ ស៊ីសងគេរៀប គេដាក់ប៉ុន្មានអាណឹងទៅតាមអ្នកធ្វើ គេដឹកមិនអស់គេមកដឹកទៀតទៅមិនមែនបន្ទុំទេ ។

សុជា៖ បើនិយាយទៅម៉ាថ្ងៃប៉ុន្មានឡាន?

ធី៖ ថ្ងៃណាច្រើនៗទៅ ថ្ងៃណាតិចៗទៅស៊ីសងតែបញ្ជីដែរគេឲ្យមក ។

សុជា៖ ច្រើនបំផុតតាមពូធ្លាប់ដឹងមកប៉ុន្មានទៅ?

ធី៖ មិនហានសន្និដ្ឋានមិនទៀង អីចឹងបានខ្ញុំថាចង់ឲ្យឃើញបញ្ជី ដូចរិទ្ធីណឹងនិយាយដែរឲ្យខ្ញុំស្មាន ខ្ញុំស្មានមិនឃើញទេ ទាល់តែយកបញ្ជីមកអោចេញថ្ងៃនេះច្រើន ថ្ងៃនេះចេញប៉ុណ្ណេះៗពិតប្រាដក អីបានការឯរមិនចង់និយាយរឿងថាវាមិនពិត ដឹងពិតប្រាកដវាស្រួល ។

សុជា៖ ចុះពេលឆ្នាំ៧៩ពូទៅណាទៀតទៅ?

ធី៖ គេបែកចេញបានពីរបីថ្ងៃខ្ញុំមិនផ្ទះវិញមកខ្ញុំអត់តាមទេឲ្យតែបានរួចទៅខ្ញុំមកផ្ទះវិញហើយ ។

សុជា៖ ពូរត់ទៅដល់ណា?

ធី៖ ខ្ញុំទៅដល់កំពង់ឆ្នាំង ដល់នេះបានចូលមក ។

សុជា៖ ពូចូលមកដល់ស្រុកនេះពីឆ្នាំណាដែរ?

ធី៖ ៧៩ណឹង ។

សុជា៖ ចុះពេលមកដល់ស្រុកវិញមានហេតុអីចំពោះពូដែរ?

ធី៖ អត់មានហេតុអីទេ ដល់ក្រោយមកគេថា គេវាមានហេតុការណ៍រហូតគេដឹងខ្ញុំធ្វើការនៅទួលស្លែងគេដឹងតាំងពី៧៩មក ហើយបងប្អូនព្រោះឯកសារអីរូបថតអីវាទុកនៅណឹងទាំងអស់ ។

សុជា៖ ចុះមកផ្ទះពូមានបានជួបម្តាយ បងប្អូនទេ?

ធី៖ ខ្ញុំជួបម្តាយខ្ញុំនៅទេតើ ហើយបងប្អូនខ្ញុំដែរគេយកសម្លាប់កោះគរវាបាត់អស់ហើយបាត់បីនាក់នៅកោះគរហើយនៅបាត់ដំបងនោះអាណឹងគាត់បាត់ម៉ានាក់ស្រីណឹងបង ។

សុជា៖ ចុះកាលណឹងម្តាយ បងប្អូនពូមានដឹងថាពូធ្វើការនៅទួលស្លែងណឹងទេ?

ធី៖ អត់ទេ ដឹងតែធ្វើទ័ពណឹងទេ ។

សុជាៈ ចុះពូរៀបការណ៍នៅក្នុងឆ្នាំណាដែរ?

ធីៈ រៀបការណ៍ក្នុងឆ្នាំ៨០ ដើមឆ្នាំ៨០ ។

សុជាៈ មុនពេលរៀបការណ៍ណឹងពូមានបាននិយាយប្រាប់គ្រួសារពូធ្វើការនៅណឹងទេ?

ធីៈ ខ្ញុំអត់បានរៀបរាប់អីទេ ព្រោះអាណឹងម្នាក់ៗចេះតែខ្លាចមិនមែនចេះតែចំហរព្រោះអាណឹងយើងវាមិនចង់ធ្វើទេ ធ្វើម៉េចគេថាក្រោមគេឲ្យទៅណាទៅណឹង ។

សុជាៈ ចុះពេលណាបានគាត់បានដឹងពីរឿងរ៉ាវទាំងអស់ណឹង?

ធីៈ ដល់ក្រោយមក៨១,៨២មកគេដឹងហើយ គេដឹងទាំងអស់គ្នាណឹងថាខ្ញុំធ្វើការនៅណឹងព្រោះគេឲ្យខាងគេឲ្យខ្ញុំទៅរៀនសូត្រមុនគេទៅកាប់ព្រៃកាប់អីណឹង ។

សុជាៈ ចុះពូគេថា ពេលគេដឹងពូធ្វើការនៅណឹងក្រោយមកមានធ្វើអីទៀត?

ធីៈ ក្រោយមកគេអត់មានធ្វើអីផង ប៉ុន្តែខ្ញុំនឹកឃើញថាបើសិនជាខ្ញុំព្រោះអីការងារអីចឹងមិនមែនខ្ញុំចង់ធ្វើដោយខ្លួនឯងផង ព្រោះអានេះនៅក្រោមបញ្ជាគេ គេចាត់តាំងមកឲ្យទៅធ្វើគេឲ្យធ្វើម៉េចធ្វើអីចឹងបើអីចឹងយើងប្រចាំងគេ ប្រចាំងគេមានតែស្លាប់ហើយបើសិនជាឃើញគេចាប់ខ្ញុំយកទៅណាទៅចុះ ហើយចុះបងប្អូនខ្ញុំប្រាប់ដែរថាអើយ ឯងធ្វើការអីចឹងឯងរត់ចេញទៅល្អហើយអនាគតវែង បើស្លាប់ណឹងត្រង់ស្លាប់ទៅធ្វើម៉េច ។

សុជាៈ ចុះកាលណឹងគេមានចាប់ពូដែរ?

ធីៈ ដល់ឆ្នាំ៨៣, ៨៤បានគេចាប់ខ្ញុំ ។

សុជាៈ ចាប់យកទៅណា?

ធីៈ ចាប់អាណឹងចាប់យកទៅភ្នំពេញ ។

សុជាៈ ពីណាគេអ្នកមកចាប់?

ធីៈ ទេអានេះអ្នកមកពីលើ ។

សុជាៈ តែគេចាប់ណឹងដោយសារមូលហេតុអី?

ធីៈ គេថាខ្ញុំមេធំនៅគុកទួលស្លែងណឹង គេអត់ដឹងប្រវត្តិពិតទេ ចុះគេឃើញខ្ញុំធ្វើបញ្ជីតាមពិតទៅរឿងអ្នកទោសគេឃើញនៅធ្វើបញ្ជីធ្វើអីចឹងថាធំហើយ បើពិតទៅហើយគេថាខ្ញុំណឹងហើយចុះការងារសរសេរបញ្ជីអ្នកទោសមក មានពីណាធ្វើមានតែខ្ញុំណឹងដល់អីចឹងមានតែខ្ញុំដល់នេះគេថាខ្ញុំជាមនុស្សអន់ៗ ។

សុជាៈ ហើយដល់ពេលគេចាប់យកទៅគេយកទៅដាក់នៅកន្លែងណាដែរ?

ធីៈ មុនដំបូងគេចាប់យកទៅភ្នំពេញណឹង ប្រហែលចូលជិតមាឆ្នាំដែរ ។

សុជាៈ ក្រោយមកគេយកទៅណា?

ធីៈ បានគេបញ្ជូនទៅ បែបស្រុកយួនហើយតាមមើល មិនដឹងជានៅឯណាទេខ្ញុំអត់ដឹងពិតប្រាកដទេ ព្រោះគេបញ្ជូនទៅគេចងបិតមុខ ចេញពីណាក៏គេបិតមុខដែរ ទៅដល់គុកនោះសុទ្ធតែគុក ងងឹតទាំងអស់គេចាប់សុទ្ធតែគុកងងឹត អត់គុកយើងភ្លឺមើលអីឃើញទេរបងខ្ពស់ណាស់មើលអត់ឃើញទេ ហើយចុលក្នុងបន្ទប់បិតជិតទាំងអស់វាមានតែប្រហោងខាងលើឯនោះ ។

សុជាៈ អាណឹងគុកងងឹត?

ធីៈ អាណឹងគុកងងឹត ។

សុជាៈ ប៉ុន្តែកាលដាក់ក្រោយណឹងមិនមែន តែកាលណឹងពូចាត់ទុកថាមិនមែននៅក្នុងស្រុកខ្មែរយើងទេ?

ធីៈ មិនមែនទេតាមមើល ។

សុជាៈ ហេតុអីបានជាពូសន្និដ្ឋានថាមិនមែនស្រុកខ្មែរយើង?

ធីៈ ព្រោះវាមានវៀត ណាមការពារដែរកាលណឹង ។

យ៉ាងៈ កាលណឹងគេចាប់ពូទៅគេមានធ្វើអីខ្លះ?

ធីៈ គេអត់ធ្វើផង មុនដំបូងយើងវាវេទនាបន្តិចហើយព្រោះនៅក្នុងគុកវាអត់មានខោអាវអីៗ អត់មានកន្ទេលស្អីៗ ធម្មតាទេគេខ្លាចយើងធ្វើអត្តឃាដ អត់មានភួយមានអីផង ។

សុជាៈ បានប៉ុន្មានឆ្នាំដែរ?

ធីៈ ទាល់គេបញ្ជូនទៅបានយើងធូរបន្តិច ។

សុជាៈ ចុះពេលណាបានពូមកវិញ?

ធីៈ ជាប់គុកប្រាំឆ្នាំបាន ។

សុជាៈ មកដល់ផ្ទះវិញនៅឆ្នាំណា?

ធីៈ ឆ្នាំ៨៧, ៨៨ហើយ ។

សុជាៈ កាលចាប់ណឹងខាងភូមិឃុំគេមកចាប់?

ធី: ចាប់ខ្ញុំណឹង មិនមែនទេខាងលើខាងខេត្ត ខាងមជ្ឈិមអីមក ។

សុជា: ចុះពេលគេចាប់ទៅប្រពន្ធពូគាត់គិតយ៉ាងម៉េចដែរ?

ធី: គាត់ចាប់ឈឺតាំងពីណឹងរហូតមក ឥឡូវទៅជាខ្សោយបេះដូង ដូចខ្ញុំនិយាយជាមួយបងធី បងប៉ាន់ ប៉ាន់រិទ្ធី រិទ្ធីប៉ាន់ គាត់មកគាត់មានអីមកនេះទេ គាត់ដឹងប្រពន្ធខ្ញុំអីចឹង គាត់នៅឆ្ងាយ គាត់កេសខ្ញុំ គាត់ដឹង ខ្ញុំប្រាប់ប្រពន្ធខ្ញុំហើយគាត់មកម៉ូតូស្វាត់ៗអត់មានឲ្យមកឡានទេ ព្រោះគាត់ខ្លាចប្រពន្ធខ្ញុំវាខ្សោយបេះដូង តាំងពីគេចាប់ខ្ញុំមករហូត ។

សុជា: ចុះពូមានដែរនិយាយរឿងរ៉ាវទាំងអស់ណឹងទេ?

ធី: រឿងរ៉ាវដែរខ្ញុំធ្វើគុកទួលស្លែងណឹង ឥឡូវគេដឹងទូទៅទាំងអស់ហើយម៉ាភូមិម៉ាឃុំណឹង ។

សុជា: ចុះដល់ពេលគេដឹងអីចឹង លោកពូគិតថាអារម្មណ៍របស់ពួកគាត់ណឹងយ៉ាងម៉េចដែរ?

ធី: ខ្ញុំវាអារម្មណ៍ខ្ញុំ?

សុជា: អារម្មណ៍ពួកគាត់?

ធី: អារម្មណ៍ពួកគាត់មិនដឹងធ្វើម៉េច គេនិយាយខាងប៉ុស្តិ៍ ខាងឃុំគេនិយាយធ្វើម៉េចក្រោមរបបគេ ការងារណឹងបើយើងមិនធ្វើក៏យើងមិនអាចរស់ជីវិតដែរគេនិយាយអីចឹងដែរ ។

សុជា: កាលពូចូលបដិវត្តន៍ដំបូងពូមានដឹងពីគោលបំណងសំខាន់នៃបដិវត្តន៍ណឹងទេ?

ធី: ដឹងកាលណឹងនឹកឃើញថាសម្តេចឪៗថាជោគជ័យយើងបានសុខសាន្តបេះតែធ្វើម៉េច គេថាយើងខំដល់តែជួយទាំងអស់គ្នាទើបឆាប់បានរំដោះ ហើយចុះអាណាចង់មានសង្គ្រាមបេះតែទៅជួយហើយ ដើម្បីបានរំដោះប្រទេសឆាប់ៗ ។

សុជា: ចុះមកដល់ឥឡូវពូមាននឹកឃើញថាស្តាយក្រោយទេ?

ធី: ខ្ញុំវានឹកឃើញថា បើសិនជាមកទល់បច្ចុប្បន្ននេះបើសិនជានឹកអីចឹងខ្ញុំមិនឲ្យខូចអនាគតអីចឹងទេខំតស៊ូរហូតដល់សឹងថ្ងៃណាក៏ថ្ងៃស្លាប់ដែរនៅក្នុងសរមភូមិ ហើយមកបានលទ្ធផលមកបានស្អុយឈ្មោះរហូតម៉ាជីវិត ។

សុជា: ពូបានឆ្លងកាត់របបខ្មែរក្រហម ខ្លួនពូផ្ទាល់បានទៅធ្វើការតែគ្រួសាររបស់ពូ បងប្អូនច្រើនបានស្លាប់នៅក្នុងរបបខ្មែរក្រហម ត្រូវគេយកទៅសម្លាប់នៅកោះគរអីចឹង ពូយល់ថារបបណឹង យ៉ាងម៉េចដែរ?

ធី: ខ្ញុំថារបបណឹង ថានៅក្នុងពិភពលោកមិនដែរមានឯណាធ្វើអីចឹងទេ តែយើងមិនអាចនិយាយបានគេកាលពីសម័យណឹងហើយដល់នឹកឃើញអីចឹង ដូចថាវាផាស់ស៊ីសណាស់សាហាវណាស់អាក្នាស្លាប់ៗអត់ដឹងរឿងអីផង ចុះយើងថាពួក១៧ មុនដំបូងយើងថាពួក១៧ចុះអស់១៧លែងអាអ្នកក្នាឯងខំតស៊ូធ្វើសង្គ្រាមមករហូតដើម្បីរំដោះប្រទេស ដល់នេះចាប់យកទៅសម្លាប់ ។

សុជា: ចុះពូថាកាលសម័យណឹងការគ្រប់គ្រងមានកន្លែងណាល្អទេ?

ធី: ការគ្រប់កាលសម័យណឹង កាលនៅធ្វើទ័ពខ្ញុំឃើញល្អណាស់ ។

សុជា: តែពេលដល់៧៥ដល់៧៩?

ធី: ៧៥-៧៩យើងមើលឃើញអត់មានល្អទេ ព្រោះការងារគេបញ្ឈាដាប់រហូតណឹងអត់មានពេលចេញទៅសួរសុខទុកបងប្អូនទេជួបជុំគ្រួសារទេ ។

## កាស្សែតទី២

សុជា: ចុះរាល់ពូថាបងពូស្លាប់ហើយ ហើយពូដឹងអ្នកដែលសម្លាប់បងពូ ហើយរស់នៅជិតខាងពូរាល់ថ្ងៃតើពូមានគំនិតចង់សងសឹកគេដែរអត់ទេ?

ធី: អានេះវាធ្វើម៉េចទេទាំងខ្ញុំទាំងគេវាថាអានេះវាក្រោមរបបវាពិបាកដនិយាយណាស់ ។

សុជា: ពូមានដែរនិយាយរឿងរ៉ាវទាំងអស់ណឹងប្រាប់កូនចៅពូដែរទេ?

ធី: រឿងខ្ញុំធ្វើទ័ពអី កូនចៅខ្ញុំមិនសួរទេ ។

សុជា: ពូគិតថារឿងរ៉ាវដែរពូបាននិយាយប្រាប់ខ្ញុំណឹង ពូគិតថានិយាយប្រាប់ក្មេងៗឲ្យបានដឹងដែររឺគួរតែបំភ្លេចចោល?

ធី: អានេះបើវាចង់ដឹងនិយាយទៅ បើថាមិនចង់ដឹងអត់ដឹងទៅ ។

សុជា: ពីមុនមកមានដែរគេមកសួរពូពីរឿងរ៉ាវអីចឹងទេ?

ធី: សួរបើនិយាយទៅមានតែរហូតតាំងពីពួកជនបរទេស អ្នកកាស្សែតអីណឹង ។

សុជា: ចុះពេលមានគេមកសួរនាំពូម្តងៗពីរឿងរ៉ាវអីចឹង ពូមានអារម្មណ៍យ៉ាងម៉េចដែរ?

ធី: ខ្ញុំថាធ្វើម៉េច ខ្ញុំនឹកឃើញថាវាអន់ចិត្តដែរ នឹកឃើញថារាល់ថ្ងៃនេះខំៗដើម្បី ហើយគេសួរតែដដែល ចុះមួយវាផ្សេងគ្នាទាំងអស់មួយមកពីខាងកាសែ្សតទៅ មួយមកខាងទូរទស្សន៍ មួយមកខាងដូចថាអង្គការនេះ មួយដូចថាមកពីអង្គការនោះទៅគេចង់ដឹង ខ្ញុំថាខ្ញុំនិយាយនេះនិយាយតែដដែល តែគេចង់បានការពិត ដូច្នេះខ្ញុំនឹកឃើញអីចឹងធម្មតាហើយព្រោះគ្នាចង់ដឹងការពិត ព្រោះដឹងពួតគេវាមិនច្បាស់ ហើយគេចង់មកផ្ទាល់អីចឹង ហើយក៏ខ្ញុំអត់មានសតិអារម្មណ៍អីដូចមុនដែរ ចេះតែឆ្លើយតាមណឹងទៅការពិតខ្ញុំដឹងទាំងប៉ុន្មានខ្ញុំឆ្លើយតាមណឹងទៅកាលដែរខ្ញុំអត់ដឹងក៏ខ្ញុំមិនអាចនិយាយបានដែរ អានេះតាមយើងដឹងប៉ុន្មាននិយាយប៉ុណ្ណឹងទៅ ។

សុជា: ចំពោះពូផ្ទាល់មកដល់រាល់ថ្ងៃនេះ ពូមានដែរដឹងរឿងរ៉ាវដែរទាក់ទងជាមួយ មេដឹកនាំខ្មែរក្រហមដែរ?

ធី: រឿងរ៉ាវទាក់ទងមេនដឹកនាំខ្មែរ?

សុជា: រឿងពត៏មានដែលទាក់ទងនិងមេដឹកនាំខ្មែរក្រហម រាល់ថ្ងៃណឹងពូមានដឹងទេ?

ធី: ខ្ញុំអត់បានដឹងរឿងរ៉ាវ ។

សុជា: ដូចថារាល់ថ្ងៃនេះគេឈានដល់ដំណាក់កាលជិតក្រោយហើយ វាម៉ាដំណាក់កាលទៀតទេ ពីរឿងបង្កើតតុលាការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមពូ តើពូពេលដែរព្វអីចឹងពូមានអារម្មណ៍ ហើយគិតថាម៉េចដែរ?

ធី: អានេះខ្ញុំយល់ឃើញថាបើគេកាត់ទោសមេដឹកនាំខ្មែរក្រហមអាណឹងយើងធម្មតាតែយើងគេទោសខ្ញុំនឹកឃើញថាធម្មតាតែគេធ្វើទោស គេធ្វើទោសតែអ្នកដែរបញ្ជា អ្នកថ្នាក់លើខ្ពស់ៗ ហើយយើងទទួលបញ្ជាគេបើតាមខ្ញុំយល់ខ្លួនឯងគេមិនអាចធ្វើដល់យើង តែបើធ្វើដល់ទៅតាមទោស ទៅតាមគេនឹកឃើញទៅខ្ញុំអត់មានថាអីណាស្អី ទៅតាមច្បាប់ទៅ ។

សុជា: ត្រង់នេះខ្ញុំសូមបញ្ជាក់ប្រាប់ពូបន្តិច គេថាច្បាប់គេបានចែងរួចទៅហើយ ហើយរដ្ឋសភាយើងហើយណឹងច្បាប់ណឹងក៏បានទទួលស្គាល់ពីអង្គការសហប្រជាជាតិដែរ ហើយអង្គការសហប្រជាជាតិណឹង រួមមានប្រទេសជាច្រើនដូចពូបានដឹងហើយថាជាង១០០ប្រទេសដែលជាសមាជិកអង្គការសហប្រជាជាតិណឹង ហើយសភាជាតិយើងក៏បានអនុម័តដែរពីរឿងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមណឹង នៅក្នុងមាត្រាដំបូងគេនៃច្បាប់ការទោសមេ

ដឹកនាំខ្មែរក្រហមណឹង គេកាត់តែអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងចន្លោះឆ្នាំ៧៥ - ៧៩ អីចឹងពូ អីចឹងបានន័យថាគេមិនយកអ្នកនៅក្រោមបង្គាប់បញ្ជានៅតាមមូលដ្ឋានរឺក៏នៅតាមភូមិភាគអី រឺក៏អ្នកដែលទទួលបញ្ជាគេគឺគេមិនយកទៅទេ បើតាមគំនិតនៃច្បាប់ណឹងពូ ហីចុះបើតាមគំនិតពូវិញចំពោះវិញ ពូចង់ឲ្យគេកាត់ទោសមេដឹកនាំត្រឹមកម្រិតណាដែរ?

ធី: ខ្ញុំបើនិយាយរាល់ថ្ងៃនេះបើសិនជា គេកាត់ទោសមេដឹកនាំខ្មែរក្រហមបានមានយុត្តិធម៌កុំឲ្យអត់មានការកាត់ទោស វាអត់មានយុត្តិធម៌ទេ ។

សុជា: ហេតុអីពូ?

ធី: ព្រោះអានេះថាបញ្ជាមកពីវាធ្វើខុសទាំងអស់ ហើយយើងដឹងខុសដែរតែយ៉ាងម៉េចដែរបានធ្វើជាមួយគេប៉ុន្តែយើងមិនអាចងាក កាលសម័យណឹងដូចយើងចង់ចេញដើរទៅឯនេះបានចង់ឯនោះបានដូចសម័យយើងឥឡូវនេះទេ របបគេថានៅឯណាណឹងហើយ ហើយបើចង់រត់ចេញមកផ្ទះគេមានសហករណ៍ យើងរត់ទៅឯណា ។

សុជា: ចុះពូផ្ទាល់ថាពូធ្វើការនៅស-២១ តើអ្នកគ្រប់គ្រងលើពូឈ្មោះឌុចអីចឹង ហើយពូគិតថាមានគេបញ្ជាត្រួតលើឌុចណឹងទៀតទេ ចំពោះការប្រព្រឹត្តិ រឺក៏ធ្វើនៅត្រឹមណឹង?

ធី: ខ្ញុំមិនអាចសន្និដ្ឋានបានទេព្រោះបញ្ជាពីលើ រឺក៏សម្រេចខ្លួនឯងខ្ញុំ ព្រោះការងារនេះវាខ្ពស់ណាស់ខ្ញុំមិនអាចដឹងទេ ។

សុជា: តែពូអាចសន្និដ្ឋានបានថាការងារណឹងសម្រេចតែត្រឹមឌុចណឹង រឺក៏មានពីណាទៀត?

ធី: ខ្ញុំមិនអាចសន្និដ្ឋានបានទេ បើថាសម្រេចត្រឹមឌុច ក្រែងមានពីលើទៀតអត់ដឹង ហើយពីលើអត់ធ្វើឌុចធ្វើក៏មិនដឹង ចំពោះខ្ញុំអត់មានរយៈទាក់ទង ព្រោះខ្ញុំដឹងថាហ៊ឹណឹងនៅពីលើខ្ញុំគេចាំតែមើលខ្ញុំធ្វើការ បញ្ជីណឹងបើនិយាយទៅការងារណឹងការងារហ៊ឹទេប៉ុន្តែខ្ញុំអ្នកសរសេរណឹង ប៉ុន្តែគេខ្ញុំធ្វើជាស្មាន អក្សរស្អាតចេះដឹងគ្រាន់បើ ។

សុជា: ខ្ញុំនិយាយមកក្រោយវិញ ថាតើការកាត់ទោសណឹងម្តងផលប្រយោជន៍សារៈសំខាន់អីដល់ប្រទេសយើងដែរ?

ធី: បើតាមខ្ញុំយល់កាត់ផ្តល់សារៈសំខាន់ដល់ប្រទេសយើងណាស់ ព្រោះវាអាចកុំឲ្យមានរបបណឹងក្រោយៗមកវាមានបន្តទៀត អានេះការយល់ដឹងរបស់ខ្ញុំទេ កុំអាងឯងដឹងនាំប្រទេសអាងអីកាប់សម្លាប់គេអីចឹងៗ ។

សុដាៈ ចុះពូគិតថាការកាត់ទោសអាចធ្វើឲ្យប៉ះពាល់ដល់ការផ្សះផ្សាជាតិ បង្រួបបង្រួមជាតិទេ ធ្វើឲ្យប្រទេសយើង អ្នកខ្លះគេយល់ប្រទ្បាំថាការកាត់ទោសណឹង អាចធ្វើឲ្យប្រទេសជាតិមានការបែកបាក់គ្នាមានសង្គ្រាម តើពូយល់ដូចណឹងទេ?

ធីៈ អានេះខ្ញុំមិនអាចសន្និដ្ឋានបានទេ អានេះគេ យើងមើលមិនដឹងទេព្រោះអាណឹងយើងមើលមិនឃើញ ។

សុដាៈ ហើយចំពោះពូ ពូយល់យ៉ាងម៉េចដែរពាក្យថាយុត្តិធម៌?

ធីៈ យុត្តិធម៌ខ្ញុំយល់ថាកុំឲ្យមានរបបសម្លាប់មនុស្សអត់ដឹងហេតុ ដឹងផលអាងតែយើងថ្នាក់ខ្ពស់បញ្ជាមកឲ្យគេធ្វើគេចាប់នេះចាប់នោះ ចោទថាគ្នាថាជាខ្មាំងជាអី ដើម្បីឲ្យមានយុត្តិធម៌ ។

សុដាៈ ខ្ញុំចង់និយាយប្រាប់ពូពីដំណើរការ នៃការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមហ្នឹងដូចខ្ញុំនិយាយប្រាប់ពូហើយខ្លឹមសារនៃច្បាប់ហ្នឹងគេកាត់តែមេដឹកនាំធំៗទេ ហើយតុលាការណឹងរាល់ថ្ងៃណឹងវាឈានដល់ដំណាក់កាលចុងក្រោយមួយហើយ គឺគេនៅតែចាំរដ្ឋាភិបាលថ្មី សភាថ្មីចូលទៅអនុម័តយកកិច្ចព្រមព្រៀងបង្កើតតុលាការកាត់សេចក្តី ទៅលើមេដឹកនាំខ្មែរក្រហម គឺសភាយើងអនុម័តយកសន្ធិសញ្ញាណឹង កិច្ចព្រមព្រៀងណឹងហើយពេលណឹងគេនិងមានអង្គតុលាការមួយចំរុះគេហៅថាចៅក្រម តុលាការចំរុះខ្មែរនិងបរទេស អង្គការសហប្រជាជាតិ ហើយតុលាការណឹងគេណឹងដំណើរការទៅរយៈពេលបីឆ្នាំតាំងពីនីតិវិធីនៃការស៊ើបអង្កេតនិងការចោទប្រកាន់អីពូ ហើយចំណាយថវិការនឹងដោយអង្គការសហប្រជាជាតិ ចំពោះរឿងណឹងពូមានដែរបានឮពីមុនមកដែរ?

ធីៈ ឮសួរគេថារៀបចំសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមណឹងឮតាមវិទ្យុ ។

សុដាៈ ព្រោះកាលខែ៦ ឆ្នាំណឹងខែមិថុនាហ្នឹង គេមានកិច្ចព្រមព្រៀងចុះដោយអគ្គលេខាធិការរងហេកូរ៉េល ទទួលបន្ទុកផ្នែកច្បាប់ណឹងជាមួយនិងឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីអីចឹងយើងនៅចាំដំណាក់កាលចុះក្រោយមួយទៀតទេ ចុះបើមានអង្គតុលាការណឹងកើតឡើង គេត្រូវការពូទៅឆ្លើយបំភ្លឺនៅក្នុងអង្គតុលាការណឹង តើពូហានទៅទេ?

ធីៈ អានេះបើគេហៅខ្ញុំទៅឲ្យឆ្លើយ ធ្វើម៉េចទៅតាមច្បាប់ទៅធ្វើម៉េច ទៅតាមកម្រិតតែខ្ញុំដឹង ។

សុដាៈ ពូមានអ៊ីចង់បន្ថែមទៀតទេ ដែលខ្ញុំមិនបានសួរពូទេ?

ធីៈ ដូចអត់មានអីបន្ថែមទេ ។

សុជាៈ អរគុណពូច្រើន ។

ធីៈ បាទ ។

សុជាៈ បទសម្ភាសន៍នេះធ្វើឡើងដោយខ្ញុំឈ្មោះសុជា និងសុខឃាង ជាមួយពូម្ចាស់ប្រវត្តិរូប ឈ្មោះសួស ធី អាយុ៥២ឆ្នាំ ដែរជាម្ចាស់ប្រវត្តិរូបនៅភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៣សម្ភាសន៍ចប់នៅវេលាម៉ោង៤,៥នាទី ។

**ចប់**